១២៩

លំហាត់គណិតវិទ្យា

រៀបរៀងដោយ : **ចង ពៅ**

១. លំហាត់

១. ចំពោះចំនួនគត់វិជ្ជមាន n និង p ដែល $p \le n$ ។

ក. បង្ហាញថា $C_n^p = C_n^{n-p}$ ។

ខ. បង្ហាញថា $C_n^p = C_{n-1}^p + C_{n-1}^{p-1}$ ។

គ. បង្ហាញថា $C_n^{p+1} = \dfrac{n-p}{p+1} C_n^p$ ។

២. បង្ហាញថា $1 \cdot 1! + 2 \cdot 2! + 3 \cdot 3! + \cdots + n \cdot n! < (n+1)!$ ។

៣. បង្ហាញថា $\dfrac{1}{0!} + \dfrac{1}{1!} + \dfrac{1}{2!} + \cdots + \dfrac{1}{n!} < 3$ ។

៤. បង្ហាញថា $C_n^0 + C_n^1 + C_n^2 + \cdots + C_n^n = 2^n$ ។

៥. បង្ហាញថា $C_{2n}^1 + C_{2n}^3 + C_{2n}^5 + \cdots + C_{2n}^{2n-1} = C_{2n}^0 + C_{2n}^2 + C_{2n}^4 + \cdots + C_{2n}^{2n}$

៦. គណនាផលបូក :

$A = 2^n C_n^0 + 2^{n-2} C_n^2 + 2^{n-4} C_n^4 + \cdots$

$B = 2^{n-1} C_n^1 + 2^{n-3} C_n^3 + 2^{n-5} C_n^5 + \cdots$

៧. បង្ហាញថា $1 \times C_n^1 + 2 \times C_n^2 + 3 \times C_n^3 + \cdots + n \times C_n^n = n \times 2^{n-1}$ ។

៨. បង្ហាញថា $2 \times 1\ C_n^2 + 3 \times 2\ C_n^3 + \cdots + n(n-1) C_n^n = n(n-1)2^{n-2}$ ។

៩. គណនាផលបូក $S = C_n^0 + \dfrac{1}{2} C_n^1 + \dfrac{1}{3} C_n^2 + \cdots + \dfrac{1}{n+1} C_n^n$ ។

១០. បង្ហាញថា $\left(C_n^0\right)^2 + \left(C_n^1\right)^2 + \left(C_n^2\right)^2 + \cdots + \left(C_n^n\right)^2 = C_{2n}^n$ ។

១១. គេឱ្យ $n \in \mathbb{N}$ ដែល $n \ge 4$ ។ បង្ហាញថា $C_{C_n^2}^2 = 3C_{n+1}^4$ ។

១២. គេតាង $P_n = \displaystyle\prod_{k=0}^{n} C_n^k$ ។ បង្ហាញថាចំពោះគ្រប់ $n \in \mathbb{N}$ គេបាន $\dfrac{P_n}{P_{n-1}} = \dfrac{n^n}{n!}$ ។

១៣. រក $\log_{30} 8$ ជាអនុគមន៍នៃ c និង d បើគេដឹងថា $\log_{30} 3 = c$ និង $\log_{30} 5 = d$ ។

១៤. រក $\log_9 40$ ជាអនុគមន៍នៃ c និង d បើគេដឹងថា $\log 15 = c$ និង $\log_{20} 50 = d$ ។

១៥. ដោះស្រាយសមីការ $x^{\log x} = 100x$ ។

១៦. ដោះស្រាយសមីការ $\dfrac{1}{\sqrt{2x-1}} = (2x-1)^{\log_{\frac{1}{4}}(1+7x-2x^2)}$ ។

១៧. ដោះស្រាយសមីការ $4^{\log x+1} - 6^{\log x} - 2\times 3^{2\log x+2} = 0$ ។

១៨. គេអោយ $a > 1$ និង $x > 1$ ដែល $\log_a(\log_a(\log_a 2) + \log_a 24 - 128) = 128$ និង $\log_a(\log_a x) = 256$ ។
រកចំនួនគត់ x ។

១៩. គេមានចំនួនកុំផ្លិច z ដែល $z \neq 0$ ។ ចូរដោះស្រាយសមីការ $2 - \dfrac{1}{z} = \bar{z}$ ។

២០. បង្ហាញថា បើផលគុណនៃ $z_1 z_2$ ជាចំនួនពិតខុសពីសូន្យ នោះមានចំនួនពិត α មួយដែល $z_1 = \alpha\bar{z_2}$

២១. ចំពោះចំនួនកុំផ្លិច z និង w ចូរបង្ហាញថា $|z+w| \leq |z| + |w|$ ។

២២. បង្ហាញថា $2+i$ ជាឫសរបស់សមីការ $z^4 - 5z^3 + 3z^2 + 19z - 30 = 0$ រួចរកឫសផ្សេងទៀតរបស់សមីការនេះ។

២៣. បង្ហាញថា $x^4 + 4 = (x-1-i)(x-1+i)(x+1+i)(x+1-i)$ ។

២៤. ដោះស្រាយសមីការ $(2+i)x^2 - (5-i)x + (2-2i) = 0$ ។

២៥. រកគ្រប់ចំនួនកុំផ្លិច $z \neq 0$ ដែល $z + \dfrac{1}{z} \in \mathbb{R}$ ។

២៦. បង្ហាញថា $z = \left(\dfrac{19+7i}{9-i}\right)^{2019} + \left(\dfrac{20+5i}{7+6i}\right)^{2019} + 19012019$ ជាចំនួនពិត។

២៧. គេឲ្យ $\tan A$ និង $\tan B$ ជាឫសនៃសមីការ $x^2 + px + q = 0$ ។ ចូររកតម្លៃនៃ:
$\sin^2(A+B) + p\sin(A+B)\cos(A+B) + q\cos^2(A+B)$ ។

២៨. គេមាន x, y និង z ជាចំនួនពិតដែល $x = \sqrt{11-2yz}, y = \sqrt{12-2xz}$, និង
$z = \sqrt{13-2xy}$ គណនាតម្លៃនៃ $x+y+z$ ។

២៩. គេឲ្យ a និង b ជាចំនួនគត់ធម្មជាតិដែលផ្ទៀងផ្ទាត់ $a + b = \dfrac{a}{b} + \dfrac{b}{a}$ ។
ចូរគណនាតម្លៃនៃ $(a^2+b^2)^{11} - 30ab$ ។

៣០. ចំពោះគ្រប់ចំនួនពិត x, y ដែលផ្ទៀងផ្ទាត់សមីការ $\log_2(2x+y) = \log_4(x^2+xy+7y^2)$ មានចំនួនពិត K ដែល
$\log_3(3x+y) = \log_9(3x^2+4xy+Ky^2)$ ។
ចូររកផលគុណនៃតម្លៃដែលអាចកើតមាននៃ K ។

៣១. គេឱ្យ x, y និង z ជាចំនួនកុំផ្លិចដែលផ្ទៀងផ្ទាត់ $xy = -80 - 320i, yz = 60$ និង
$zx = -96 + 24i$ ។ ចូរគណនា $|x+y+z|$ ។

៣២. ក្នុងតម្រុយអរតូណរម៉ាល់ $(O, \vec{i}, \vec{j}, \vec{k})$ មានទិសដៅវិជ្ជមាន គេមានស្វ៊ែ (S) មួយមានផ្ចិត $C(a,b,c)$។ បង្ហាញថាបើ
ស្វ៊ែ (S) ប៉ះនឹងប្លង់ (yz) នោះ កាំនៃស្វ៊ែនោះគឺ $r = |a|$ ។

៣៣. បើ $x>0, y>0,\ \log_y x+\log_x y=\dfrac{10}{3}$ និង $xy=144$ គណនាតម្លៃនៃ $\dfrac{x+y}{2}$ ។

៣៤. បើ $R_n=\dfrac{1}{2}(a^n+b^n)$ ដែល $a=3+2\sqrt{2},\ b=3-2\sqrt{2}$ និង
$n=0,1,2,3,4,\dots$ គេបាន R_{12345} ជាចំនួនគត់។ ចូររកលេខខ្ទង់រាយនៃ R_{12345} ។

៣៥. បង្ហាញថា $z(1-z)(1+z+z^2)(1+z+z^3)(z+z^5)=z^2-1$ ដែល $z=\cos\dfrac{2\pi}{5}+i\sin\dfrac{2\pi}{5}$

៣៦. គេឲ្យ $S=\underbrace{111\dots1}_{2n\text{ ខ្ទង់នៃលេខ1}}+\underbrace{444\dots4}_{n\text{ ខ្ទង់នៃលេខ4}}+1$ ។ បង្ហាញថា S ជាការេនៃចំនួនគត់។

៣៧. បង្ហាញថាចំពោះគ្រប់ចំនួនគត់វិជ្ជមាន n គេបាន
$z=(2018-i2019)^{2020^n}+(2018+i2019)^{2020^n}$ ជាចំនួនពិត។

៣៨. គេឲ្យវ៉ិចទ័រ $\vec{a},\vec{b}$ និង $\vec{c}$ ផ្ទៀងផ្ទាត់ $\vec{a}\times\vec{b}=\vec{b}\times\vec{c}=\vec{c}\times\vec{a}\neq\vec{0}$ ។ បង្ហាញថា $\vec{a}+\vec{b}+\vec{c}=\vec{0}$ ។

៣៩. រកម៉ូឌុល និងអាគុយម៉ង់នៃចំនួនកុំផ្លិច z ដែល $z=\dfrac{(2\sqrt{3}+2i)^8}{(1-i)^6}+\dfrac{(1+i)^6}{(2\sqrt{3}-2i)^8}$ ។

៤០. គណនាផលសងរួម d នៃស្វ៊ីតនព្វន្តមួយ ដោយដឹងថាបើគេថែម 3 លើផលសងរួម នោះផលបូក n តួដំបូងកើនឡើងពីរដង ហើយបើតួទីមួយកើនឡើងបួនដង នោះផលបូក n តួដំបូងកើនឡើងពីរដងដែរ។

៤១. គេមានត្រីកោណ ABC និង A,B,C ជាមុំក្នុងត្រីកោណនេះ។
ក. បើគេដឹងថា $\sin A+\sin B+\sin C=1$ គណនា $\cos\dfrac{A}{2}\cos\dfrac{B}{2}\cos\dfrac{C}{2}$ ។
ខ. បង្ហាញថា $\cos^2 A+\cos^2 B+\cos^2 C=1-\cos A\cos B\cos C$ ។

៤២. គេឲ្យ a,b,c ជាបីចំនួនពិតខុសគ្នា និងខុសពីសូន្យ ដែលផ្ទៀងផ្ទាត់
$a+\dfrac{1}{b}=b+\dfrac{1}{c}=c+\dfrac{1}{a}$ ។ បង្ហាញថា $|abc|=1$ ។

៤៣. រកគ្រប់ចំនួនពិត x ដែល $\dfrac{8^x+27^x}{12^x+18^x}=\dfrac{7}{6}$ ។

៤៤. គណនា $S=\dfrac{3}{1!+2!+3!}+\dfrac{4}{2!+3!+4!}+\cdots+\dfrac{2019}{2017!+2018!+2019!}$

៤៥. គណនាលីមីត
ក. $\lim\limits_{x\to\frac{\pi}{2}}\left(x\tan x-\dfrac{\pi}{2\cos x}\right)$ ខ. $\lim\limits_{x\to\frac{\pi}{3}}\left(\dfrac{x}{2}-\dfrac{\pi}{3}\cos x\right)\cdot\dfrac{1}{x-\frac{\pi}{3}}$ ។

៤៦. រកគ្រប់តម្លៃ x ដែលផ្ទៀងផ្ទាត់សមីការ $2^x+3^x-4^x+6^x-9^x=1$ ។

៤៧. គេឲ្យ x,y និង z ជាចំនួនកុំផ្លិចដែលផ្ទៀងផ្ទាត់ $x+y+z=2, x^2+y^2+z^2=3$ និង $xyz=4$ ។ គណនា
$\dfrac{1}{xy+z-1}+\dfrac{1}{yz+x-1}+\dfrac{1}{zx+y-1}$ ។

៤៨. គេមានចំនួនកុំផ្លិច $z=\cos\theta+i\sin\theta$ ដែល $0\le\theta\le 2\pi$ ។
បង្ហាញថា $\dfrac{2}{1+z}=1-i\tan\dfrac{\theta}{2}$ ។

៤៩. ក. ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n បង្ហាញថា

$$(\sqrt{3}-i)^n=2^n\left(\cos\frac{n\pi}{6}-i\sin\frac{n\pi}{6}\right)\ ។$$

ខ. ដោយដឹងថា $\sqrt{3}-i$ ជាឫសនៃសមីការ $x^9+16(1+i)x^3+a+ib=0$ ។

ចូររកចំនួនពិត a និង b ។

៥០. បើ $a>1,b>1$ បង្ហាញថា $2(ab+1)>(a+1)(b+1)$ ។

៥១. រកគ្រប់ចំនួនពិត x,y,z ដែលផ្ទៀងផ្ទាត់សមីការ

$$\frac{4x^2}{1+4x^2}=y\ ,\ \frac{4y^2}{1+4y^2}=z\ ,\ \frac{4z^2}{1+4z^2}=x$$

៥២. ប្រៀបធៀបចំនួន $\log_3 108\ ,\ \log_4 192\ ,\ \log_5 500\ ,\ \log_6 1080$ ។

៥៣. បង្ហាញថា $\dfrac{2}{x^2-1}+\dfrac{4}{x^2-4}+\dfrac{6}{x^2-9}+\cdot+\dfrac{20}{x^2-100}$

$$=11\left[\frac{1}{(x-1)(x+10)}+\frac{1}{(x-2)(x+9)}+\cdots+\frac{1}{(x-10)(x+1)}\right]$$

៥៤. គេមាន a,b,c,d ជាឫសនៃសមីការ $x^4-\pi x-\sqrt{2019}=0$ ។
ចូររកសមីការដែលមានឫស $\dfrac{a+b+c}{d^2}\ ,\ \dfrac{b+c+d}{a^2}\ ,\ \dfrac{c+d+a}{b^2}\ ,\ \dfrac{d+a+b}{c^2}$ ។

៥៥. រកសមីការដែលមានដឺក្រេតូចបំផុត ហើយមានមេគុណជាចំនួនគត់ និងមាន
$\sqrt{19}+\sqrt{99}$ ជាឫសមួយរបស់វា។

៥៦. បើ a,b,c,x ជាចំនួនពិត ដែល $a+b+c\neq 0$ និង

$$\frac{xb+(1-x)c}{a}=\frac{xc+(1-x)a}{b}=\frac{xa+(1-x)b}{c}$$

បង្ហាញថា $a=b=c$ ។

៥៧. តាង a,b,c ជាចំនួនពិតវិជ្ជមានដែល $a+b+c=1$ ។

តាង $\lambda=\min\{a^3+a^2bc,b^2+ab^2c,c^3+abc^2\}$ ។ បង្ហាញថាសមីការ $x^2+x+4\lambda=0$ មានឫសពីរជាចំនួនពិត។

៥៨. ចំពោះចំនួនពិតខុសពីសូន្យ x,y,z ដែល $\dfrac{1}{x}+\dfrac{1}{y}+\dfrac{1}{z}=0$ ។
បង្ហាញថា $\dfrac{yz}{x^2}+\dfrac{zx}{y^2}+\dfrac{xy}{z^2}=3$ ។

៥៩. រកចំនួនគត់ a និង b ដែលនាំឱ្យ x^2-x-1 ចែកដាច់ $ax^{17}+bx^{16}+1$ ។

បើ p,q,r ជាឫសនៃសមីការ $x^3-3px^2+3q^2x-r^3=0$ ។ បង្ហាញថា $p=q=r$

៦០. គេឱ្យ (u_n) ជាស្វ៊ីតកំណត់លើ $\mathbb{N}$ ដោយ $u_n=\left\lfloor(2+\sqrt{3})^n\right\rfloor$ ។

បង្ហាញថា $(2+\sqrt{3})^n+(2-\sqrt{3})^n$ ជាចំនួនគត់គូ រួចទាញថា u_n ជាចំនួនគត់សេស។

៦១. គេឱ្យ $a_n=3n+\sqrt{n^2-1}$ និង $b_n=2\left(\sqrt{n^2-n}+\sqrt{n^2+n}\right)$

ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ។ បង្ហាញថា

$\sqrt{a_1-b_1}+\sqrt{a_2-b_2}+\cdots+\sqrt{a_{49}-b_{49}}=A+B\sqrt{2}$ ចំពោះចំនួនគត់ A និង B ។

៦២. គេឱ្យ (u_n) ជាស្វ៊ីតកំណត់លើ $\mathbb{N}$ ដោយ $u_n=\left\lfloor(2+\sqrt{3})^n\right\rfloor$ ។

បង្ហាញថា $(2+\sqrt{3})^n+(2-\sqrt{3})^n$ ជាចំនួនគត់គូ រួចទាញថា u_n ជាចំនួនគត់សេស។

៦៣. គេឱ្យ $a_n=3n+\sqrt{n^2-1}$ និង $b_n=2\left(\sqrt{n^2-n}+\sqrt{n^2+n}\right)$

ចំពោះគ្រប់ចំនួនគត់វិជ្ជមាន n ។ បង្ហាញថា

$\sqrt{a_1-b_1}+\sqrt{a_2-b_2}+\cdots+\sqrt{a_{49}-b_{49}}=A+B\sqrt{2}$ ចំពោះចំនួនគត់ A និង B ។

៦៤. គេឱ្យ $a_n=\sqrt{1+\left(1+\frac{1}{n}\right)^2}+\sqrt{1+\left(1-\frac{1}{n}\right)^2}$ ដែល n ជាចំនួនគត់វិជ្ជមាន។ បង្ហាញថា $\frac{1}{a_1}+\frac{1}{a_2}+\cdots+\frac{1}{a_{20}}$ ជាចំនួនគត់វិជ្ជមាន។

៦៥. តាង $f(n)=(n^2+n+1)^2+1$ ។ គេកំណត់ស្វ៊ីត

$U_n=\dfrac{f(1)\times f(3)\times f(5)\times\cdots\times f(2n-1)}{f(2)\times f(4)\times f(6)\times\cdots\times f(2n)}$ ដែល $n\in\mathbb{N}$។

គណនា $\lim_{n\to\infty}\left(n\sqrt{U_n}\right)$ ។

៦៦. គេឱ្យស្វ៊ីតពីរ (a_n) និង (b_n) ជាស្វ៊ីតនៃចំនួនពិតធម្មជាតិដែលផ្ទៀងផ្ទាត់

$a_n+\sqrt{2}b_n=(2+\sqrt{2})^n$ ។ គណនា $\lim_{n\to\infty}\dfrac{a_n}{b_n}$ ។

៦៧. គេឱ្យស្វ៊ីត (u_n) កំណត់ដោយ $u_{n+2}=5u_{n+1}-6u_n$ ចំពោះ $n\in\mathbb{N}$ និង (v_n) ជាស្វ៊ីតមួយទៀតដែល

$v_n=u_{n+1}-au_n$ ។ កំណត់តម្លៃនៃចំនួនពិត a ដើម្បីឱ្យ (v_n) ជាស្វ៊ីតធរណីមាត្រ។

៦៨. ត្រីកោណ ABC មួយមានរង្វាស់ជ្រុង $x,\ x+1$ និង $x+2$ ជាត្រីកោណសមញ្ញដែលមានមុំទាលមួយ។ ចូររកវ៉ង់នៃតម្លៃ x ។

៦៩. ចំពោះចំនួនគត់វិជ្ជមាន n និង $a_n=19^n+(-1)^{n-1}\cdot 2^{4n-3}$ ។ រកចំនួនបឋមតូចបំផុតដែលចែកដាច់ a_n ។

៧០. ចំពោះចំនួនពិត a គេមានចំណុច $A(a,0)$ និង $B(-a,0)$ ។ ចូររកសំណុំចំណុច P នៅក្នុងប្លង់មួយដែលបំពេញលក្ខខណ្ឌ $\angle APB=90^\circ$ ។

៧១. ឧបមាថាចំណុច P ស្ថិតនៅលើប៉ារ៉ាបូល $y^2 = ax$ ហើយមិនស្ថិតនៅលើគល់ $O(0,0)$ ។ គេគូសបន្ទាត់មួយកែងនឹងប៉ារ៉ាបូលត្រង់ P ។ តាង Q ជាចំណុចប្រសព្វរវាងបន្ទាត់កែងនឹងអ័ក្សអាប់ស៊ីស ហើយ R ជាចំណុចប្រសព្វរវាងចំណោលកែងត្រង់ P លើអ័ក្សអាប់ស៊ីស។ ស្រាយបញ្ជាក់ថា ប្រវែងអង្កត់ QR មានតម្លៃថេរ មិនទាក់ទងនឹងទីតាំងរបស់ P ទេ។

៧២. បន្ទាត់ដែលមានសមីការ $x + y + 1 = 0$ កាត់រង្វង់ដែលមានសមីការ $x^2 + y^2 = 4$ ត្រង់ពីរចំណុចផ្សេងគ្នា។ គេគូសបន្ទាត់ប៉ះទៅនឹងរង្វង់ត្រង់ចំណុចប្រសព្វទាំងពីរនោះ។ តាង θ ជាមុំដែលបង្កើតឡើងដោយបន្ទាត់ប៉ះទាំងពីរនោះ ហើយគេដឹងថា $0 \le \theta \le 90^\circ$ ។ រកតម្លៃនៃ $\tan\theta$ ។

៧៣. តាង a, b និង c ជាជ្រុងនៃត្រីកោណមួយ ហើយ S ជាផ្ទៃក្រឡានៃត្រីកោណនោះ និង $a + b + c = 2p$។ ចូរបង្ហាញថា $p^2 \ge 3\sqrt{3}S$ ។

៧៤. ចូរស្រាយបញ្ជាក់ថា ប្រសិនបើចំនួនពិត x, y, z និង a បំពេញលក្ខខណ្ឌ
$x + y + z = a$ និង $x^3 + y^3 + z^3 = a^3$ នាំឱ្យយ៉ាងហោចណាស់មានមួយក្នុងចំណោម
x, y និង z ស្មើនឹង a ។

៧៥. ចូរស្រាយបញ្ជាក់ថា ប្រសិនបើចំនួនពិត x, y, z និង a បំពេញលក្ខខណ្ឌ
$x + y + z = 3a$ និង $xy + yz + zx = 3a^2$ នាំឱ្យ $x = y = z = a$ ។

៧៦. ចំពោះចំនួនគត់វិជ្ជមាន n បើ $a_n > 0$ ហើយផ្ទៀតផ្ទាត់ $\sum_{j=1}^{n} a_j^3 = \left(\sum_{j=1}^{n} a_j\right)^2$ ។
ចូរស្រាយបញ្ជាក់ថា $a_n = n$ ។

៧៧. គណនាលីមីតខាងក្រោម

ក. $\lim\limits_{n\to+\infty} \sum_{k=1}^{n} \frac{\sqrt{k}}{n\sqrt{n}}$

ខ. $\lim\limits_{x\to1} \left(\frac{1}{1-x} - \frac{n}{1-x^n}\right)$, $n \in \mathbb{N}$

៧៨. ដោះស្រាយសមីការខាងក្រោម

ក. $5^x \times 2^{\frac{2x-1}{x+1}} = 50$

ខ. $\log_3\left(\sqrt{1+x^2} + x\right) = \log_2\left(\sqrt{1+x^2} - x\right)$

៧៩. ដោះស្រាយវិសមីការ $x^2 + (x+1)^2 \le \dfrac{15}{x + (x+1)}$ ។

៨០. បង្ហាញថាដេរីវេ $f'(x)$ នៃអនុគមន៍ $f(x) = (x+2)e^{-x}$ ជាអនុគមន៍កើនដាច់ខាតចំពោះ $x > 0$

៨១. រកសមីការបន្ទាត់ប៉ះនៃអេលីប $9x^2 + 16y^2 = 52$ ហើយស្របនឹងបន្ទាត់ $9x - 8y = 1$ ។

៨២. គេមានស្វ៊ីតចំនួនពិត (u_n) និង (v_n) ដែលកំណត់ដោយ $u_0 = 0, v_0 = 1$ និង $\begin{cases} u_{n+1} = \dfrac{u_n + v_n}{2} \\ v_{n+1} = \dfrac{u_n + 2v_n}{3} \end{cases}$ ចំពោះ $\forall n \in \mathbb{N}$ ។ X_n និង A ជាពីរម៉ាទ្រីសដែល $X_n = \begin{pmatrix} u_n \\ v_n \end{pmatrix}$ និង $A = \begin{pmatrix} \frac{1}{2} & \frac{1}{2} \\ \frac{1}{3} & \frac{2}{3} \end{pmatrix}$ ។

ក. បង្ហាញថាចំពោះគ្រប់ $n \in \mathbb{N}$ គេបាន $X_n = A^n X_0$ ។

ខ. P, P' និង B ជាម៉ាទ្រីសដែល $P = \begin{pmatrix} \frac{4}{5} & \frac{6}{5} \\ -\frac{6}{5} & \frac{6}{5} \end{pmatrix}$, $P' = \begin{pmatrix} \frac{1}{2} & -\frac{1}{2} \\ \frac{1}{2} & \frac{1}{3} \end{pmatrix}$ និង $B = \begin{pmatrix} 1 & 0 \\ 0 & \frac{1}{6} \end{pmatrix}$

១. គណនា PP' និងបង្ហាញថា $P'BP = A$ រួចគណនា A^n ។

២. កំណត់តួទូទៅនៃស្វ៊ីត (u_n) និង (v_n) ។

៨៣. ដោះស្រាយសមីការ $\log_{\sin x} \cos x + \log_{\cos x} \sin x = 2$ ។

៨៤. គេឱ្យ A ជាម៉ាទ្រីសការេដែល $A^2 = I$ ហើយ I ជាម៉ាទ្រីសឯកតា។

សម្រួលកន្សោម $(A - I)^3 + (A + I)^3 - 7A$ ។

៨៥. រកតម្លៃអតិបរមានៃ $\begin{vmatrix} 1 & 1 & 1 \\ 1 & 1 + \sin\theta & 1 \\ 1 & 1 & 1 + \cos\theta \end{vmatrix}$ ។

៨៦. គណនា $L = \sum_{s=1}^{10} \sum_{r=0}^{s-1} (2^s - 2^r)$ ។

៨៧. គេមានសំណុំ $S = \{a \in \mathbb{N}, 1 \le a \le 100\}$ និងសមីការ

$\lfloor \tan^2 x \rfloor - \tan x - a = 0$ មានឫសជាចំនួនពិត។ កំណត់ចំនួនធាតុនៃ S ។

($\lfloor x \rfloor$ តាងឱ្យផ្នែកគត់ធំបំផុត $\le x$)

៨៨. គេមាន $x = \sin\dfrac{2\pi}{7} + \sin\dfrac{4\pi}{7} + \sin\dfrac{8\pi}{7}$ និង

$y = \cos\dfrac{2\pi}{7} + \cos\dfrac{4\pi}{7} + \cos\dfrac{8\pi}{7}$ ។ គណនាតម្លៃនៃ $x^2 + y^2$ ។

៨៩. គេឱ្យ $f(x) = \displaystyle\int_0^{g(x)} \frac{dt}{\sqrt{1 + t^3}}$ និង $g(x) = \displaystyle\int_0^{\cos x} (1 + \sin t^2)dt$ ។

គណនា $f'\left(\dfrac{\pi}{2}\right)$ ។

៩០. គេឱ្យ $\dfrac{dy}{dx} = \dfrac{(x+1)^2 + y - 3}{x + 1}$ និង $y(1) = 1$ ។ រកតម្លៃអប្បបរមានៃ $y(x)$ ។

៩១. រកវ៉ង់នៃអនុគមន៍ $f(x)=\dfrac{2\sin^2 x+2\sin x+3}{\sin^2 x+\sin x+1}$ ។

៩២. គណនា $\displaystyle\int_{1/8}^{\sin^2 x}\left(\sin^{-1}\sqrt{t}\right)dt+\int_{1/8}^{\cos^2 x}\left(\cos^{-1}\sqrt{t}\right)dt$ ដែល $0\le x\le\dfrac{\pi}{2}$ ។

៩៣. គេឱ្យ z និង z_0 ជាចំនួនកុំផ្លិចដែល $|z-i|\le 2$ និង $z_0=5+3i$ ។

គណនាតម្លៃអតិបរមានៃ $|iz+z_0|$ ។

៩៤. គេឱ្យអនុគមន៍ $g(x)$ ជាប់លើចន្លោះ $(0,+\infty)$ ផ្ទៀងផ្ទាត់ $g(1)=1$ និង
$\displaystyle\int_0^x 2xg^2(t)dt=\left(\int_0^x 2g(x-t)dt\right)^2$ ។ កំណត់អនុគមន៍ g ។

៩៥. គេមាន a,b,c ជាឫសនៃសមីការ $px^3+qx^2+r=0$ ។

ចូរគណនាដេទែមីណង់ $\Delta=\begin{vmatrix}\frac{1}{a}&\frac{1}{b}&\frac{1}{c}\\ \frac{1}{b}&\frac{1}{c}&\frac{1}{a}\\ \frac{1}{c}&\frac{1}{a}&\frac{1}{b}\end{vmatrix}$ ។

៩៦. គេឱ្យ $\tan A=\dfrac{x^2-x}{x^2-x+1}$ និង $\tan B=\dfrac{1}{2x^2-2x+1}$ ដែល $0<A,B<\dfrac{\pi}{2}$ ។
គណនា $A+B$ ។

៩៧. គេឱ្យបន្ទាត់ $L_1:\dfrac{x+1}{3}=\dfrac{y+2}{1}=\dfrac{z+1}{2}$ និងបន្ទាត់ $L_2:\dfrac{x-2}{1}=\dfrac{y+2}{2}=\dfrac{z-3}{3}$ ។ រកវ៉ិចទ័រឯកតា $\vec{p}$ ដែលអរត្តូកូណាល់នឹងបន្ទាត់ទាំងពីរនេះ។

៩៨. គេឱ្យ α និង β ជាឫសនៃសមីការ $x^2-6x-2=0$ ដែល $\alpha>\beta$ ។ តាង $t_n=\alpha^n-\beta^n$ ។ គណនាតម្លៃនៃ $\dfrac{t_{22}-2t_{20}}{2t_{21}}$ ។

៩៩. គេឱ្យ f ជាអនុគមន៍មានដេរីវេលើ $(0,+\infty)$ ហើយផ្ទៀងផ្ទាត់ $f(1)=1$ និង
$\displaystyle\lim_{t\to x}\frac{t^2f(x)-x^2f(t)}{t-x}=1$ ចំពោះ $x>0$ ។ កំណត់អនុគមន៍ $f(x)$ ។

១០០. គណនាអាំងតេក្រាល $I=\displaystyle\int_{\sqrt{\ln 2}}^{\sqrt{\ln 3}}\frac{x\sin x^2}{\sin x^2+\sin(\ln 6-x^2)}dx$ ។

១០១. គេឱ្យ A ជាម៉ាទ្រីសការេ និងផ្ទៀងផ្ទាត់ $A^2=I$ ។ រកម៉ាទ្រីសច្រាសនៃ A ។

១០២. គេមានម៉ាទ្រីស $A=\begin{bmatrix}1&\sin\theta&1\\-\sin\theta&1&\sin\theta\\-1&-\sin\theta&1\end{bmatrix}$ ។ រកវ៉ង់នៃ $|A|$ ។

១០៣. គេឱ្យ $\vec{a}$ និង $\vec{b}$ ជាពីរវ៉ិចទ័រឯកតា និងមិនកូលីនេអ៊ែរគ្នា។ បើ $\vec{u} = \vec{a} - (\vec{a}\cdot\vec{b})\vec{b}$ និង $\vec{v} = \vec{a}\times\vec{b}$ បង្ហាញថា $|\vec{v}| = |\vec{u}| + |\vec{u}\cdot\vec{b}|$ ។

១០៤. គណនាផលបូក $\dfrac{1}{1!(n-1)!} + \dfrac{1}{3!(n-3)!} + \dfrac{1}{5!(n-5)!} + \cdots + \dfrac{1}{(n-1)!1!}$ ។

១០៥. គេមាន $\sin^3 x \sin 3x = \sum\limits_{m=0}^{n} C_m \cos(mx)$ ដែល $C_0, C_1, \cdots, C_n$ ជាចំនួនពិត និង $C_n \neq 0$ ។ រកតម្លៃនៃ n ។

១០៦. គណនាតម្លៃនៃកន្សោម $\sin\dfrac{\pi}{14}\sin\dfrac{3\pi}{14}\sin\dfrac{5\pi}{14}\sin\dfrac{7\pi}{14}\sin\dfrac{9\pi}{14}\sin\dfrac{13\pi}{14}$ ។

១០៧. គណនាតម្លៃនៃកន្សោម $L = \sin\dfrac{\pi}{18}\sin\dfrac{5\pi}{18}\sin\dfrac{7\pi}{18}$ ។

១០៨. គេឱ្យ $A > 0, B > 0$ និង $A + B = \dfrac{\pi}{3}$ ។ រកតម្លៃអតិបរមានៃកន្សោម $y = \tan A \tan B$ ។

១០៩. ដោះស្រាយសមីការ $\cos^7 x + \sin^4 x = 1$ លើចន្លោះ $(-\pi, \pi)$ ។

១១០. គេឱ្យ $A = \sin^2 x + \cos^4 x$ ។ ចំពោះគ្រប់តម្លៃនៃចំនួនពិត x រកវ៉ែងនៃ A ។

១១១. ដោះស្រាយសមីការ $\sin x - 3\sin 2x + \sin 3x = \cos x - 3\cos 2x + \cos 3x$

១១២. រកតម្លៃអតិបរមានៃ $\cos x_1 \cos x_2 \cos x_3 \cdots \cos x_n$ បើគេដឹងថា $0 \le x_1, x_2, x_3, \ldots, x_n \le \dfrac{\pi}{2}$ និង $\cot x_1 \cot x_2 \cot x_3 \cdots \cot x_n = 1$ ។

១១៣. ប្រៀបធៀប $t_1 = (\tan\theta)^{\tan\theta}, t_2 = (\tan\theta)^{\cot\theta}, t_3 = (\cot\theta)^{\tan\theta}$ និង $t_4 = (\cot\theta)^{\cot\theta}$ ចំពោះ $\theta \in \left(0, \dfrac{\pi}{4}\right)$ ។

១១៤. គណនា $S = \sum\limits_{k=1}^{13} \dfrac{1}{\sin\left(\dfrac{\pi}{4} + \dfrac{(k-1)\pi}{6}\right)\sin\left(\dfrac{\pi}{4} + \dfrac{k\pi}{6}\right)}$ ។

១១៥. គណនា $\left(1+\cos\dfrac{\pi}{8}\right)\left(1+\cos\dfrac{3\pi}{8}\right)\left(1+\cos\dfrac{5\pi}{8}\right)\left(1+\cos\dfrac{7\pi}{8}\right)$ ។

១១៦. សម្រួលកន្សោម $3\left[\sin^4\left(\dfrac{3\pi}{2} - \alpha\right) + \sin^4(3\pi + \alpha)\right] - 2\left[\sin^6\left(\dfrac{\pi}{2} + \alpha\right) + \sin^6(5\pi - \alpha)\right]$ ។

១១៧. រកតម្លៃនៃ θ ដែល $0 \le \theta \le \dfrac{\pi}{2}$ ហើយផ្ទៀងផ្ទាត់

$$\begin{vmatrix} 1+\sin^2\theta & \cos^2\theta & 4\sin 4\theta \\ \sin^2\theta & 1+\cos^2\theta & 4\sin 4\theta \\ \sin^2\theta & \cos^2\theta & 1+4\sin 4\theta \end{vmatrix} = 0 \quad ។$$

១១៨. បង្ហាញថា

ក. $(\sin 12^\circ)(\sin 48^\circ)(\sin 54^\circ) = \dfrac{1}{8}$

ខ. $16\cos\dfrac{2\pi}{15}\cos\dfrac{4\pi}{15}\cos\dfrac{8\pi}{15}\cos\dfrac{16\pi}{15} = 1$

១១៩. រកគ្រប់តម្លៃនៃ $x \in (-\pi, \pi)$ ដែលផ្ទៀងផ្ទាត់ $8^{1+|\cos x|+|\cos^2 x|+|\cos^3 x|+\cdots} = 4^3$ ។

១២០. បង្ហាញថា $\tan x + 2\tan 2x + 4\tan 4x + 8\cot 8x = \cot x$ ។

១២១. រកតម្លៃនៃចំនួនពិតវិជ្ជមានតូចបំផុត x (គិតជាដឺក្រេ) ដែលផ្ទៀងផ្ទាត់

$$\tan(x+100^\circ) = \tan(x+50^\circ)\tan x\tan(x-50^\circ) \text{ ។}$$

១២២. ស្វ៊ីត (a_n) បំពេញលក្ខខណ្ឌខាងក្រោមចំពោះគ្រប់ $n = 1, 2, 3, \ldots$ ។

$$\sum_{k=1}^{n}\frac{1}{k}\left(a_k + \frac{1}{k+1}\right) = 2^n + 1 - \frac{1}{n+1} \text{ ។}$$

ក. រកតួទី n នៃស្វ៊ីត (a_n) ជាអនុគមន៍នៃ n ។

ខ. គណនា $\sum_{k=1}^{n} a_k$ ។

១២៣. គណនាលីមីតខាងក្រោម

ក. $\lim_{x\to 1}\dfrac{\sqrt[3]{x^2} - 2\sqrt[3]{x} + 1}{(x-1)^2}$

ខ. $\lim_{x\to 3}\left[\log_a\left(\dfrac{x-3}{\sqrt{x+6}-3}\right)\right] \quad , a > 0, a \neq 1$

គ. $\lim_{x\to 0}\dfrac{1-\cos^3 x}{x\sin x\cos x}$

១២៤. គណនាលីមីតខាងក្រោម

ក. $\lim_{x\to 1}\sum_{r=1}^{n}\dfrac{x^r - 1}{x-1}$

ខ. $\lim_{n\to+\infty}\dfrac{1}{n^4}\left[\left(\sum_{k=1}^{n} k\right) + 2\left(\sum_{k=1}^{n-1} k\right) + 3\left(\sum_{k=1}^{n-2} k\right) + \cdots + n\right]$

គ. $\lim_{n\to+\infty}\prod_{r=3}^{n}\left(\dfrac{r^3-1}{r^3+1}\right)$

១២៥. គណនាលីមីត $\lim_{n\to+\infty}\dfrac{1}{n^3}\left(\sum_{k=1}^{n}\lfloor k^2 x\rfloor\right)$ ដែល $\lfloor x\rfloor$ តាងឱ្យផ្នែកគត់ ធំបំផុត $\leq x$ ។

១២៦. គណនាលីមីត $\lim_{n\to+\infty}\left(\cos\dfrac{x}{2}\cos\dfrac{x}{2^2}\cos\dfrac{x}{2^3}\cdots\cos\dfrac{x}{2^n}\right)$ ។

១២៧. គណនាលីមីត $\lim_{n\to+\infty}\left(\dfrac{7}{10} + \dfrac{29}{10^2} + \dfrac{133}{10^3} + \cdots + \dfrac{5^n + 2^n}{10^n}\right)$ ។

១២៨. គណនាលីមីត $\lim_{n\to+\infty}\left(\tan\theta+\frac{1}{2}\tan\frac{\theta}{2}+\frac{1}{2}\tan\frac{\theta}{2^2}+\cdots+\frac{1}{2^n}\tan\frac{\theta}{2^n}\right)$ ។

១២៩. គណនាលីមីត $\lim_{x\to0}\frac{\tan(\lfloor-\pi^2\rfloor x^2)-x^2\tan(\lfloor-\pi^2\rfloor)}{\sin^2 x}$ ។

១៣០. គណនាលីមីត $\lim_{h\to0}\frac{2\left[\sqrt{3}\sin\left(\frac{\pi}{6}+h\right)-\cos\left(\frac{\pi}{6}+h\right)\right]}{\sqrt{3}h(\sqrt{3}\cos h-\sin h)}$ ។

១៣១. គេឱ្យ $f(x)=x-\lfloor x\rfloor$ ។ គណនាលីមីត $\lim_{n\to+\infty}\frac{[f(x)]^{2n}-1}{[f(x)]^{2n}+1}$ ។

១៣២. គណនាលីមីត $\lim_{x\to0}\frac{729^x-243^x-81^x+9^x+3^x-1}{x^3}$ ។

១៣៣. គេឱ្យ α និង β ជាឫសនៃសមីការដឺក្រេទី២ $ax^2+bx+c=0$ ។

គណនាលីមីត $\lim_{x\to\alpha}(1+ax^2+bx+c)^{\frac{1}{x-\alpha}}$ ។

១៣៤. គណនាលីមីតខាងក្រោម

ក. $\lim_{x\to a}\left(\frac{\sin x}{\sin a}\right)^{\frac{1}{x-a}}$, $a\neq k\pi,\ k\in\mathbb{Z}$

ខ. $\lim_{x\to0}\left(\frac{1+\tan x}{1-\tan x}\right)^{\frac{1}{\sin x}}$

គ. $\lim_{x\to a}\left(2-\frac{x}{a}\right)^{\tan\frac{\pi x}{2a}}$, $a\neq0$

ឃ. $\lim_{x\to0}(\cos x+a\sin bx)^{\frac{a}{x}}$

ង. $\lim_{x\to0}\left(\frac{\sin x}{x}\right)^{\frac{\sin x}{x-\sin x}}$

ច. $\lim_{x\to-1}\left(\frac{x^4+x^2+x+1}{x^2-x+1}\right)^{\frac{1-\cos(x+1)}{(x+1)^2}}$

ឆ. $\lim_{n\to+\infty}\left(\cos\frac{x}{n}\right)^n$

១៣៥. គណនាលីមីត $\lim_{x\to5}\frac{x^2-9x+20}{x-\lfloor x\rfloor}$ ដែល $\lfloor x\rfloor$ តាងឱ្យផ្នែកគត់ធំបំផុត $\le x$ ។

១៣៦. គណនាលីមីត $\lim_{n\to+\infty}\frac{\{x\}+\{2x\}+\{3x\}+\cdots+\{nx\}}{n^2}$

ដែល $\{k\}=k-\lfloor k\rfloor$ ផ្នែកទសភាគនៃ k ។

១៣៧. បើ $5^{1+x}+5^{1-x},\frac{a}{2}$ និង 25^x+25^{-x} ជាបីចំនួនតគ្នានៃស្វ៊ីតនព្វន្ត បង្ហាញថា $a\ge12$ ។

១៣៨. ចំពោះចំនួនពិតវិជ្ជមានខុសពីមួយ x,y,z បើ $1,\log_y x,\log_z y,-15\log_x z$ ជាតួតគ្នានៃស្វ៊ីតនព្វន្ត ។ បង្ហាញថា $x=z^3$ ។

១៣៩. គេមានបីចំនួនពិតវិជ្ជមាន a,b,c ជាបីចំនួនតគ្នានៃស្វ៊ីតនព្វន្ត និង $abc=4$ ។ រកតម្លៃអប្បបរមានៃ b ។

១៤០. គណនាផលបូក $\frac{1^4}{1\cdot3}+\frac{2^4}{3\cdot5}+\frac{3^4}{5\cdot7}+\cdots+\frac{n^4}{(2n-1)(2n+1)}$ ។

១៤១. រកតម្លៃអតិបរមានៃផលបូកស៊េរី $20+19\frac{1}{3}+18\frac{2}{3}+18+\cdots$ ។ (សម្គាល់ $19\frac{1}{3}$ ជាចំនួនចម្រុះ)

១៤២. ចំពោះចំនួនពិតវិជ្ជមាន a និង r ចូរគណនាផលបូក n តួដំបូងនៃស្វ៊ីត $\log a, \log(ar), \log(ar^2), \ldots$ ។

១៤៣. តាង S_n ជាផលបូក n តួនីមួយៗនៃស្វ៊ីតនព្វន្តនេះជាចំនួនវិជ្ជមាន និងផលសងរួម d ដែល $d = S_n - kS_{n-1} + S_{n-2}$ ។ ចូររកតម្លៃនៃចំនួនពិត k ។

១៤៤. គេឱ្យ a, b, c ជាចំនួនពិតវិជ្ជមាន និងជាតម្លៃនៃតួទី x, y, z រៀងគ្នា នៃស្វ៊ីតធរណីមាត្រមួយ។ ចូរគណនា $(y-z)\log a + (z-x)\log b + (x-y)\log c$ ។

១៤៥. គេឱ្យតួទី $p+q$ នៃស្វ៊ីតធរណីមាត្រមួយគឺ a ដែល និងតួទី $p-q$ គឺ b ដែល $a > 0, b > 0,\ p, q$ ជាចំនួនគត់ និង $p > q$ ។ គណនាតម្លៃនៃតួទី p នៃស្វ៊ីតនេះ។

១៤៦. គេឱ្យស្វ៊ីតធរណីមាត្រមួយដែលមានតួទី n តាងដោយ a_n និង $a_n > 0,\ \forall n \in \mathbb{N}$។ បើ $\sum_{k=1}^{100} a_{2k} = \alpha$ និង $\sum_{k=1}^{100} a_{2k-1} = \beta$ រកផលធៀបរួមនៃស្វ៊ីតធរណីមាត្រនេះ។

១៤៧. គណនាផលបូក n តួដំបូងនៃស្វ៊ីត $\frac{1}{2}, \frac{3}{4}, \frac{7}{8}, \frac{15}{16}, \ldots$ ។

១៤៨. គណនាផលបូកនៃស៊េរី $\frac{x}{1-x^2} + \frac{x^2}{1-x^4} + \frac{x^4}{1-x^8} + \cdots$ ដែល $|x| < 1$។

១៤៩. គណនាផលបូក

$$\frac{3}{1\cdot 2}\cdot\frac{1}{2} + \frac{4}{2\cdot 3}\cdot\left(\frac{1}{2}\right)^2 + \frac{5}{3\cdot 4}\cdot\left(\frac{1}{2}\right)^3 + \cdots + \frac{n+2}{n(n+1)}\cdot\left(\frac{1}{2}\right)^n \text{ ។}$$

១៥០. គេឱ្យ a, b, c ជាចំនួនពិតវិជ្ជមាន។ រកតម្លៃតូចបំផុតនៃកន្សោម

$$a^{\log b - \log c} + b^{\log c - \log a} + c^{\log a - \log b} \text{។}$$

១៥១. គណនាផលបូកនៃគ្រប់ចំនួនគត់ធម្មជាតិតូចជាង 200 ដែលចែកមិនដាច់នឹង 3 ឬ 5 ។

១៥២. គណនា $\sum_{i=1}^{n}\sum_{j=1}^{i}\sum_{k=1}^{j} 1$ ។

១៥៣. គណនាផលបូកនៃស៊េរី $\frac{9}{5^2\cdot 2\cdot 1} + \frac{13}{5^3\cdot 3\cdot 2} + \frac{17}{5^4\cdot 4\cdot 3} + \cdots$ ។

១៥៤. ចំពោះចំនួនគត់សេស $n \geq 1$ គណនាផលបូក

$$n^3 - (n-1)^3 + (n-2)^3 - (n-3)^3 + \cdots + (-1)^{n-1}1^3 \text{ ។}$$

១៥៥. គេឱ្យ p, q, r ជាចំនួនពិតវិជ្ជមានដែល $27pqr \geq (p+q+r)^3$ និង $3p + 4q + 5r = 12$ ។ គណនាតម្លៃនៃ $p^3 + q^4 + r^5$ ។

១៥៦. គណនាផលបូក

$$S_n = \frac{1}{1+1^2+1^4} + \frac{2}{1+2^2+2^4} + \frac{3}{1+3^2+3^4} + \cdots + \frac{n}{1+n^2+n^4} \text{ ។}$$

១៥៧. បើ $\sum_{n=1}^{+\infty} x^{n-1} = a$ និង $\sum_{n=1}^{+\infty} y^{n-1} = b$ ដែល $|x| < 1, |y| < 1$ ។

គណនា $\sum_{n=1}^{+\infty} (xy)^{n-1}$ ជាអនុគមន៍នៃ a, b ។

១៥៨. បើ $\lambda = \sum_{i=1}^{+\infty} \frac{1}{i^4}$ ។ គណនា $\sum_{i=1}^{+\infty} \frac{1}{(2i-1)^4}$ ជាអនុគមន៍នៃ λ ។

១៥៩. រកតម្លៃអប្បរមានៃកន្សោម $8^{\sin\frac{x}{8}} + 8^{\cos\frac{x}{8}}$ ។

១៦០. រកមេគុណនៃ x^{49} នៃផលគុណ $(x-1)(x-3)\cdots(x-99)$ ។

១៦១. គណនាផលបូក

$$\frac{1^3}{1} + \frac{1^3+2^3}{1+3} + \frac{1^3+2^3+3^3}{1+3+5} + \cdots + \frac{1^3+2^3+3^3+\cdots+9^3}{1+3+5+\cdots+17} \text{ ។}$$

១៦២. គណនាផលបូកនៃស៊េរី $\sum_{n=1}^{+\infty} \frac{2n-1}{(\sqrt{2})^n}$ ។

១៦៣. គេមាន $S_n = \sum_{r=0}^{n} \frac{1}{C(n,r)}$ និង $P_n = \sum_{r=0}^{n} \frac{r}{C(n,r)}$ ដែល $C(n,r) = \frac{n!}{r!(n-r)!}$ ។ គណនា $\frac{P_n}{S_n}$ ។

១៦៤. រកតួទូទៅនៃស្វ៊ីតដែលផ្ទៀងផ្ទាត់ $x_0 = 3, x_1 = 4$ និង $x_{n+1} = x_{n-1}^2 - nx_n$ ចំពោះគ្រប់ $n \in \mathbb{N}$។

១៦៥. គេឱ្យ $x_1, x_2, ..., x_n$ ជាស្វ៊ីតនៃចំនួនគត់ដែលផ្ទៀងផ្ទាត់

(i) $-1 \le x_i \le 2$, ចំពោះ $i = 1, 2, ..., n$

(ii) $x_1 + x_2 + \cdots + x_n = 19$

(iii) $x_1^2 + x_2^2 + \cdots + x_n^2 = 99$

រកតម្លៃតូចបំផុត និងធំបំផុតនៃ $x_1^3 + x_2^3 + \cdots + x_n^3$ ។

១៦៦. ចំពោះស្វ៊ីតនៃចំនួនពិត $A = \{a_1, a_2, a_3, ...\}$ តាង ΔA ជាស្វ៊ីតនៃ $\{a_2 - a_1, a_3 - a_2, a_4 - a_3, ...\}$ ។ បើគ្រប់តួនៃស្វ៊ីត $\Delta(\Delta A)$ ស្មើនឹង 1 និង $a_{19} = a_{92} = 0$ ចូររក a_1 ។

១៦៧. គេមាន $(a_n)_{n\ge1}$ ជាស្វ៊ីតនៃចំនួនពិត ដែល $a_1 = 2$ និង

$a_{n+1} = \frac{a_n}{2} + \frac{1}{a_n}$, $\forall n \in \mathbb{N}$ ។ កំណត់តួទូទៅនៃស្វ៊ីតនេះ។

១៦៨. ABC ជាត្រីកោណមួយដែលមាន $\sin(2A+B) = \sin(C-A) = -\sin(B+2C) = \frac{1}{2}$

បើ A, B និង C ជាបីចំនួនតគ្នានៃស្វ៊ីតនព្វន្ត ចូររកតម្លៃនៃមុំ A, B និង C ។

១៦៩. បង្ហាញថា $\sum_{k=1}^{n-1} (n-k)\cos\frac{2k\pi}{n} = -\frac{n}{2}$ ចំពោះគ្រប់ចំនួនគត់ $n \ge 3$ ។

២. ដំណោះស្រាយ

លំហាត់ទី ១. ចំពោះចំនួនគត់វិជ្ជមាន n និង p ដែល $p \leq n$ ។

ក. បង្ហាញថា $C_n^p = C_n^{n-p}$ ។

ខ. បង្ហាញថា $C_n^p = C_{n-1}^p + C_{n-1}^{p-1}$ ។

គ. បង្ហាញថា $C_n^{p+1} = \dfrac{n-p}{p+1} C_n^p$ ។

ដំណោះស្រាយ

ក. បង្ហាញថា $C_n^p = C_n^{n-p}$

គេមាន $C_n^p = \dfrac{n!}{p!(n-p)!} = \dfrac{n!}{(n-p)![n-(n-p)]!} = C_n^{n-p}$

ដូចនេះ $\boxed{C_n^p = C_n^{n-p}}$

ខ. បង្ហាញថា $C_n^p = C_{n-1}^p + C_{n-1}^{p-1}$

$$\begin{aligned}
\text{គេមាន } C_{n-1}^p + C_{n-1}^{p-1} &= \frac{(n-1)!}{p!(n-p-1)!} + \frac{(n-1)!}{(p-1)!\,(n-p)!} \\
&= \frac{(n-1)!}{(p-1)!\,(n-p-1)} \left(\frac{1}{p} + \frac{1}{n-p} \right) \\
&= \frac{(n-1)!}{(p-1)!\,(n-p-1)!} \times \frac{n-p+p}{p(n-p)} \\
&= \frac{n(n-1)!}{p(p-1)!\,(n-p)(n-p-1)!} \\
&= \frac{n!}{p!\,(n-p)!} = C_n^p
\end{aligned}$$

ដូចនេះ $\boxed{C_n^p = C_{n-1}^p + C_{n-1}^{p-1}}$

គ. បង្ហាញថា $C_n^{p+1} = \dfrac{n-p}{p+1} C_n^p$

គេមាន $C_n^{p+1} = \dfrac{n!}{(p+1)!(n-p-1)!} = \dfrac{n-p}{p+1} \times \dfrac{n!}{p!(n-p)!} = \dfrac{n-p}{p+1} C_n^p$

ដូចនេះ $\boxed{C_n^{p+1} = \dfrac{n-p}{p+1} C_n^p}$

លំហាត់ទី ២. បង្ហាញថា $1 \cdot 1! + 2 \cdot 2! + 3 \cdot 3! + \cdots + n \cdot n! < (n+1)!$ ។

ដំណោះស្រាយ

ចំពោះ $\forall k \in \mathbb{N}$ គេបាន $k \cdot k! = [(k+1)-1]k! = (k+1)k! - k! = (k+1)! - k!$

$$\left.\begin{array}{ll} \text{បើ } k=1: & 1 \cdot 1 = \cancel{2!} - 1! \\ \text{បើ } k=2: & 2 \cdot 2 = \cancel{3!} - \cancel{2!} \\ \text{បើ } k=3: & 3 \cdot 3! = \cancel{4!} - \cancel{3!} \\ \cdots\cdots & \cdots\cdots\cdots\cdots \\ \text{បើ } k=n: & n \cdot n! = (n+1)! - \cancel{n!} \end{array}\right\} +$$

គេបាន $1 \cdot 1! + 2 \cdot 2! + 3 \cdot 3! + \cdots + n \cdot n! = (n+1)! - 1! < (n+1)!$

ដូចនេះ $\boxed{1 \cdot 1! + 2 \cdot 2! + 3 \cdot 3! + \cdots + n \cdot n! < (n+1)!}$

លំហាត់ទី ៣. បង្ហាញថា $\frac{1}{0!} + \frac{1}{1!} + \frac{1}{2!} + \cdots + \frac{1}{n!} < 3$ ។

ដំណោះស្រាយ

ចំពោះ $\forall k \in \mathbb{N},\ k \geq 2$

គេបាន $\frac{1}{k!} = \frac{1}{1 \times 2 \times \cdots \times (k-1) \times k} < \frac{1}{(k-1)k}$

នាំឱ្យ $\frac{1}{k!} < \frac{1}{k-1} - \frac{1}{k}$

$$\left.\begin{array}{ll} \text{បើ } k=2: & \frac{1}{2!} < \frac{1}{1} - \cancel{\frac{1}{2}} \\ \text{បើ } k=3: & \frac{1}{3!} < \cancel{\frac{1}{2}} - \cancel{\frac{1}{3}} \\ \text{បើ } k=4: & \frac{1}{4!} < \cancel{\frac{1}{3}} - \cancel{\frac{1}{4}} \\ \cdots\cdots & \cdots\cdots\cdots\cdots \\ \text{បើ } k=n: & \frac{1}{n!} < \cancel{\frac{1}{n-1}} - \frac{1}{n} \end{array}\right\} +$$

គេបាន $\frac{1}{2!} + \frac{1}{3!} + \frac{1}{4!} + \cdots + \frac{1}{n!} < 1 - \frac{1}{n} < 1$

នាំឱ្យ $\frac{1}{0!} + \frac{1}{1!} + \frac{1}{2!} + \frac{1}{3!} + \cdots + \frac{1}{n!} < 1 + \frac{1}{0!} + \frac{1}{1!} = 3$

ដូចនេះ $\boxed{\frac{1}{0!}+\frac{1}{1!}+\frac{1}{2!}+\frac{1}{3!}+\cdots+\frac{1}{n!}<3}$

លំហាត់ទី ៤. បង្ហាញថា $C_n^0+C_n^1+C_n^2+\cdots+C_n^n=2^n$ ។

ដំណោះស្រាយ

តាមទ្វេធា $Newton$ គេបាន $(x+y)^n=\sum_{k=0}^{n}C_n^k x^k y^{n-k}$

យក $x=y=1$

គេបាន $(1+1)^n=\sum_{k=0}^{n}C_n^k 1^k 1^{n-k}=\sum_{k=0}^{n}C_n^k=C_n^0+C_n^1+C_n^2+\cdots+C_n^n$

ដូចនេះ $\boxed{C_n^0+C_n^1+C_n^2+\cdots+C_n^n=2^n}$

លំហាត់ទី ៥. បង្ហាញថា $C_{2n}^1+C_{2n}^3+C_{2n}^5+\cdots+C_{2n}^{2n-1}=C_{2n}^0+C_{2n}^2+C_{2n}^4+\cdots+C_{2n}^{2n}$

ដំណោះស្រាយ

តាមទ្វេធា $Newton$ គេបាន $(x-y)^{2n}=\sum_{k=0}^{2n}(-1)^k C_{2n}^k\ x^k y^{2n-k}$

យក $x=y=1$ គេបាន

$(1-1)^{2n}=\sum_{k=0}^{2n}(-1)^k 2n^k=C_{2n}^0-C_{2n}^1+C_{2n}^2-C_{2n}^3+C_{2n}^4-C_{2n}^5-\cdots-C_{2n}^{2n-1}+C_{2n}^{2n}$

$0=C_{2n}^0-C_{2n}^1+C_{2n}^2-C_{2n}^3+C_{2n}^4-C_{2n}^5-\cdots-C_{2n}^{2n-1}+C_{2n}^{2n}$

$\Longleftrightarrow C_{2n}^1+C_{2n}^3+C_{2n}^5+\cdots+C_{2n}^{2n-1}=C_{2n}^0+C_{2n}^2+C_{2n}^4+\cdots+C_{2n}^{2n}$

ដូចនេះ $\boxed{C_{2n}^1+C_{2n}^3+C_{2n}^5+\cdots+C_{2n}^{2n-1}=C_{2n}^0+C_{2n}^2+C_{2n}^4+\cdots+C_{2n}^{2n}}$

លំហាត់ទី ៦. គណនាផលបូក :

$A=2^nC_n^0+2^{n-2}C_n^2+2^{n-4}C_n^4+\cdots$

$B=2^{n-1}C_n^1+2^{n-3}C_n^3+2^{n-5}C_n^5+\cdots$

ដំណោះស្រាយ

តាមទ្វធា $Newton$ គេបាន $(x+y)^n=\sum_{k=0}^{n}C_n^k x^{n-k}y^k$ និង $(x-y)^n=\sum_{k=0}^{n}(-1)^k C_n^k x^{n-k}y^k$ គេបាន

$$A+B=\left(2^nC_n^0+2^{n-2}C_n^2+2^{n-4}C_n^4+\cdots\right)+\left(2^{n-1}C_n^1+2^{n-3}C_n^3+2^{n-5}C_n^5+\cdots\right)$$
$$=2^nC_n^0+2^{n-1}C_n^1+2^{n-2}C_n^2+2^{n-3}C_n^3+2^{n-4}C_n^4+2^{n-5}C_n^5+\cdots$$

$$= (2+1)^n$$
$$= 3^n \quad (1)$$
$$A - B = \left(2^n C_n^0 + 2^{n-2} C_n^2 + 2^{n-4} C_n^4 + \cdots\right) - \left(2^{n-1} C_n^1 + 2^{n-3} C_n^3 + 2^{n-5} C_n^5 + \cdots\right)$$
$$= 2^n C_n^0 - 2^{n-1} C_n^1 + 2^{n-2} C_n^2 - 2^{n-3} C_n^3 + 2^{n-4} C_n^4 - 2^{n-5} C_n^5 + \cdots$$
$$= (2-1)^n$$
$$= 1 \quad (2)$$

តាម (1) និង (2) គេបាន $\begin{cases} A + B = 3^n \\ A - B = 1 \end{cases} \Longleftrightarrow A = \dfrac{1}{2}(3^n + 1)$ និង $B = \dfrac{1}{2}(3^n - 1)$

ដូចនេះ $\boxed{A = \dfrac{1}{2}(3^n + 1) \ \text{ និង } \ B = \dfrac{1}{2}(3^n - 1)}$

លំហាត់ទី ៧. បង្ហាញថា $1 \times C_n^1 + 2 \times C_n^2 + 3 \times C_n^3 + \cdots + n \times C_n^n = n \times 2^{n-1}$ ។

ដំណោះស្រាយ

គេមាន $(x+1)^n = \sum_{k=0}^{n} C_n^k x^k$ ធ្វើដេរីវេធៀបអង្គទាំងពីរ

គេបាន $n(x+1)^{n-1} = \sum_{k=0}^{n} C_n^k \left(kx^{k-1}\right) = \sum_{k=0}^{n} kC_n^k x^{k-1}$

យក $x = 1$ នាំឱ្យ $n2^{n-1} = \sum_{k=0}^{n} kC_n^k = 1 \times C_n^1 + 2 \times C_n^2 + 3 \times C_n^3 + \cdots + n \times C_n^n$

ដូចនេះ $\boxed{C_n^1 + 2 \times C_n^2 + 3 \times C_n^3 + \cdots + n \times C_n^n = n \times 2^{n-1}}$

លំហាត់ទី ៨. បង្ហាញថា $2 \times 1\ C_n^2 + 3 \times 2\ C_n^3 + \cdots + n(n-1)C_n^n = n(n-1)2^{n-2}$ ។

ដំណោះស្រាយ

គេមាន $(x+1)^n = \sum_{k=0}^{n} C_n^k x^k$ ធ្វើដេរីវេធៀបអង្គទាំងពីរ

គេបាន $n(x+1)^{n-1} = \sum_{k=0}^{n} C_n^k \left(kx^{k-1}\right) = \sum_{k=0}^{n} kC_n^k x^{k-1}$

ធ្វើដេរីវេម្តងទៀតធៀបអង្គទាំងពីរ គេបាន

$$n(n-1)(x+1)^{n-2} = \sum_{k=0}^{n} k(k-1)C_n^k x^{k-2} = \sum_{k=2}^{n} k(k-1)C_n^k x^{k-2}$$

យក $x = 1$ គេបាន $n(n-1)2^{n-2} = \sum_{k=2}^{n} k(k-1)C_n^k = 2 \times 1\ C_n^2 + 3 \times 2\ C_n^3 + \cdots + n(n-1)C_n^n$

ដូចនេះ $\boxed{2\times 1\, C_n^2 + 3\times 2\, C_n^3 + \cdots + n(n-1)C_n^n = n(n-1)2^{n-2}}$

លំហាត់ទី ៩. គណនាផលបូក $S = C_n^0 + \frac{1}{2}C_n^1 + \frac{1}{3}C_n^2 + \cdots + \frac{1}{n+1}C_n^n$ ។

ដំណោះស្រាយ

គេមាន $(x+1)^n = \sum_{k=0}^{n} C_n^k x^k$ ធ្វើអាំងតេក្រាលលើរបអង្គទាំងពីរ

គេបាន $\int_0^1 (x+1)^n dx = \int_0^1 \sum_{k=0}^{n} C_n^k x^k\, dx = \sum_{k=0}^{n} C_n^k \int_0^1 x^k\, dx$

$\Longrightarrow \left.\frac{(x+1)^{n+1}}{n+1}\right|_0^1 = \sum_{k=0}^{n} C_n^k \left.\frac{x^{k+1}}{k+1}\right|_0^1$

ឬ $\frac{2^{n+1}}{n+1} - \frac{1}{n+1} = \sum_{k=0}^{n} C_n^k \left(\frac{1}{k+1} - 0\right) = \sum_{k=0}^{n} \frac{1}{k+1}C_n^k$

គេបាន $S = \sum_{k=0}^{n} \frac{1}{k+1}C_n^k = C_n^0 + \frac{1}{2}C_n^1 + \frac{1}{3}C_n^2 + \cdots + \frac{1}{n+1}C_n^n = \frac{2^{n+1}-1}{n+1}$

ដូចនេះ $\boxed{S = \frac{2^{n+1}-1}{n+1}}$

លំហាត់ទី ១០. បង្ហាញថា $\left(C_n^0\right)^2 + \left(C_n^1\right)^2 + \left(C_n^2\right)^2 + \cdots + \left(C_n^n\right)^2 = C_{2n}^n$ ។

ដំណោះស្រាយ

គេមាន $(1+x)^{2n} = (1+x)^n(1+x)^n = (1+x)^n(x+1)^n \quad (1)$

ដោយ

$(1+x)^{2n} = C_{2n}^0 + C_{2n}^1 x + C_{2n}^2 x^2 + \cdots + C_{2n}^n x^n + \cdots + C_{2n}^{2n} x^{2n} \quad (2)$

$(1+x)^n = C_n^0 + C_n^1 x + C_n^2 x^2 + \cdots + C_n^{n-1} x^{n-1} + C_n^n x^n \quad (3)$

$(x+1)^n = C_n^0 x^n + C_n^1 x^{n-1} + C_n^2 x^{n-2} + \cdots + C_n^{n-1} x + C_n^n \quad (4)$

គេបាន មេគុណនៃ x^n របស់សមភាព (2) គឺ C_{2n}^n

និង មេគុណនៃ x^n របស់សមភាព $(3)\times(4)$ គឺ $\left(C_n^0\right)^2 + \left(C_n^1\right)^2 + \left(C_n^2\right)^2 + \cdots + \left(C_n^n\right)^2$

តាម (1) គេបាន $C_{2n}^n = \left(C_n^0\right)^2 + \left(C_n^1\right)^2 + \left(C_n^2\right)^2 + \cdots + \left(C_n^n\right)^2$

ដូចនេះ $\boxed{C_{2n}^n = \left(C_n^0\right)^2 + \left(C_n^1\right)^2 + \left(C_n^2\right)^2 + \cdots + \left(C_n^n\right)^2}$

លំហាត់ទី ១១. គេឱ្យ $n \in \mathbb{N}$ ដែល $n \geq 4$ ។ បង្ហាញថា $C_{C_n^2}^2 = 3C_{n+1}^4$ ។

ដំណោះស្រាយ

គេមាន $C_{C_n^2}^2=\dfrac{(C_n^2)!}{2!\left(C_n^2-2\right)!}=\dfrac{C_n^2\left(C_n^2-1\right)\left(C_n^2-2\right)!}{2!\left(C_n^2-2\right)!}=\dfrac{\frac{n!}{2!(n-2)!}\left(\frac{n!}{2!(n-2)!}-1\right)}{2!}$

$$=\frac{\frac{n(n-1)}{2}\left(\frac{n(n-1)}{2}-1\right)}{2}=\frac{n(n-1)(n^2-n-2)}{2\times 4}=\frac{n(n-1)(n+1)(n-2)}{2\times 4}$$

$$=3\times\frac{(n-2)(n-1)n(n+1)}{2\times 3\times 4}=3\times\frac{(n-3)!(n-2)(n-1)n(n+1)}{4!(n-3)!}$$

$$=3\times\frac{(n+1)!}{4![(n+1)-4]!}=3C_{n+1}^4$$

ដូចនេះ $\boxed{C_{C_n^2}^2=3C_{n+1}^4}$

លំហាត់ទី ១២. គេតាង $P_n=\prod_{k=0}^{n}C_n^k$ ។ បង្ហាញថាចំពោះគ្រប់ $n\in\mathbb{N}$ គេបាន $\dfrac{P_n}{P_{n-1}}=\dfrac{n^n}{n!}$ ។

ដំណោះស្រាយ

គេមាន $\dfrac{P_n}{P_{n-1}}=\dfrac{\prod_{k=0}^{n}C_n^k}{\prod_{k=0}^{n-1}C_{n-1}^k}=\dfrac{\left(\prod_{k=0}^{n-1}C_n^k\right)C_n^n}{\prod_{k=0}^{n-1}C_{n-1}^k}=\prod_{k=0}^{n-1}\dfrac{C_n^k}{C_{n-1}^k}$

$$=\prod_{k=0}^{n-1}\left(\frac{\frac{n!}{k!(n-k)!}}{\frac{(n-1)!}{k!(n-k-1)!}}\right)=\prod_{k=0}^{n-1}\frac{n}{n-k}$$

នាំឱ្យ $\dfrac{P_n}{P_{n-1}}=\dfrac{n}{n}\times\dfrac{n}{n-1}\times\dfrac{n}{n-2}\times\dfrac{n}{n-3}\times\cdots\times\dfrac{n}{2}\times\dfrac{n}{1}=\boxed{\dfrac{n^n}{n!}}$

លំហាត់ទី ១៣. រក $\log_{30}8$ ជាអនុគមន៍នៃ c និង d បើគេដឹងថា $\log_{30}3=c$ និង $\log_{30}5=d$

ដំណោះស្រាយ

គេមាន $\log_{30}8=3\log_{30}2=3\log_{30}\left(\dfrac{30}{15}\right)=3\left(\log_{30}30-\log_{30}15\right)$

$$=3\left(1-\log_{30}3-\log_{30}5\right)=3(1-c-d)$$

ដូចនេះ $\boxed{\log_{30} 8 = 3(1-c-d)}$

លំហាត់ទី ១៤. រក $\log_9 40$ ជាអនុគមន៍នៃ c និង d បើគេដឹងថា $\log 15 = c$ និង $\log_{20} 50 = d$

ដំណោះស្រាយ

គេមាន

$$\log_9 40 = \frac{\log 40}{\log 9} = \frac{\log 4 + \log 10}{2\log 3} = \frac{2\log 2 + 1}{2\log 3}$$

$$c = \log 15 = \log 3 + \log 5$$

$$d = \log_{20} 50 = \frac{\log 50}{\log 20} = \frac{\log 5 + \log 10}{\log 2 + \log 10} = \frac{\log 5 + 1}{\log 2 + 1}$$

សម្គាល់

$\log_a b = \dfrac{\log_c b}{\log_c a}$ (រូបមន្តប្តូរគោល)

ចំពោះ $a > 0, b > 0, c > 0, a \neq 1, c \neq 1$

តាង $x = \log 2,\ y = \log 3$ និង $z = \log 5$ គេបាន $\begin{cases} \log_9 40 = \dfrac{2x+1}{2y} \\ c = y + z \\ d = \dfrac{z+1}{x+1} \end{cases}$

តែ $x + z = \log 2 + \log 5 = \log 10 = 1$

គេបាន $\begin{cases} x + z = 1 \\ y + z = c \\ \dfrac{z+1}{x+1} = d \end{cases} \iff \begin{cases} y + (1-x) = c \\ \dfrac{1-x+1}{x+1} = d \end{cases} \iff \begin{cases} y - x = c - 1 \\ x = \dfrac{2-d}{1+d} \end{cases}$

$$\iff \begin{cases} y = \dfrac{c - 2d + cd + 1}{1+d} \\ x = \dfrac{2-d}{1+d} \end{cases}$$

គេបាន $\log_9 40 = \dfrac{2x+1}{2y} = \dfrac{2\left(\dfrac{2-d}{1+d}\right)+1}{2\left(\dfrac{c-2d+cd+1}{1+d}\right)} = \dfrac{4-2d+1+d}{2(c-2d+cd+1)}$

$$\log_9 40 = \frac{5-d}{2(c-2d+cd+1)}$$

ដូចនេះ $\boxed{\log_9 40 = \dfrac{5-d}{2(c-2d+cd+1)}}$

លំហាត់ទី ១៥. ដោះស្រាយសមីការ $x^{\log x} = 100x$ ។

ដំណោះស្រាយ

សមីការមានន័យកាលណា $x > 0$

គេបាន $x^{\log x} = 100x \Longrightarrow \log x^{\log x} = \log 100x$

$\Longrightarrow \log^2 x = \log 100 + \log x = 2 + \log x \Longleftrightarrow \log^2 x - \log x - 2 = 0$

$\Longleftrightarrow \log x = -1 \lor \log x = 2 \Longleftrightarrow x = \dfrac{1}{10} \lor x = 100$

ដូចនេះ $\boxed{\text{សមីការមានចម្លើយ } x = \dfrac{1}{10} \lor x = 100}$

លំហាត់ទី ១៦. ដោះស្រាយសមីការ $\dfrac{1}{\sqrt{2x-1}} = (2x-1)^{\log_{\frac{1}{4}}(1+7x-2x^2)}$ ។

ដំណោះស្រាយ

សមីការមានន័យកាលណា

$$\begin{cases} 2x - 1 > 0 \\ 1 + 7x - 2x^2 > 0 \end{cases} \Longleftrightarrow \begin{cases} x > \dfrac{1}{2} \\ \dfrac{7-\sqrt{57}}{4} < x < \dfrac{7+\sqrt{57}}{4} \end{cases}$$

$\Longleftrightarrow \dfrac{1}{2} < x < \dfrac{7+\sqrt{57}}{4} \quad (1)$

គេបាន $\dfrac{1}{\sqrt{2x-1}} = (2x-1)^{\log_{\frac{1}{4}}(1+7x-2x^2)} \quad (2)$

$\Longleftrightarrow (2x-1)^{-\frac{1}{2}} = (2x-1)^{\log_{\frac{1}{4}}(1+7x-2x^2)}$

− បើ $2x - 1 = 1 \Longleftrightarrow x = 1$ គេបាន (2) ពិត

− បើ $2x - 1 \neq 1 \Longleftrightarrow x \neq 1$ តាម (2) គេបាន

$\log_{\frac{1}{4}}(1 + 7x - 2x^2) = -\dfrac{1}{2} \Longleftrightarrow -\dfrac{1}{2}\log_2(1 + 7x - 2x^2) = -\dfrac{1}{2}$

$\Longleftrightarrow 1 + 7x - 2x^2 = 2 \Longleftrightarrow 2x^2 - 7x + 1 = 0$

គេបាន $x = \dfrac{7-\sqrt{41}}{4} \lor x = \dfrac{7+\sqrt{41}}{4}$

តាម (1) $\Longrightarrow x = \dfrac{7+\sqrt{41}}{4}$

ដូចនេះ $\boxed{\text{សមីការមានចម្លើយ } x = 1 \lor x = \dfrac{7+\sqrt{41}}{4}}$

លំហាត់ទី ១៧. ដោះស្រាយសមីការ $4^{\log x+1} - 6^{\log x} - 2\times 3^{2\log x+2} = 0$ ។

ដំណោះស្រាយ

សមីការមានន័យកាលណា $x > 0$

គេមាន $4^{\log x+1} - 6^{\log x} - 2\times 3^{2\log x+2} = 0 \Longleftrightarrow 4\times 4^{\log x} - 6^{\log x} - 18\times 9^{\log x} = 0 \;\; (1)$

ចែកអង្គទាំងពីរនៃ (1) នឹង 4^x គេបាន $4 - \left(\frac{3}{2}\right)^{\log x} - 18\left(\frac{9}{4}\right)^{\log x} = 0$

តាង $t = \left(\frac{3}{2}\right)^{\log x}$, $t > 0$ គេបាន $18t^2 + t - 4 = 0 \Longleftrightarrow t = \frac{16}{36} = \left(\frac{3}{2}\right)^{-2}$

នាំឱ្យ $\left(\frac{3}{2}\right)^{\log x} = \left(\frac{3}{2}\right)^{-2} \Longleftrightarrow \log x = -2 \Longleftrightarrow x = \frac{1}{100}$

ដូចនេះ $\boxed{\text{សមីការមានចម្លើយ } x = \frac{1}{100}}$

លំហាត់ទី ១៨. គេអោយ $a > 1$ និង $x > 1$ ដែល $\log_a(\log_a(\log_a 2) + \log_a 24 - 128) = 128$ និង $\log_a(\log_a x) = 256$ ។ រកចំនួនគត់ x ។

ដំណោះស្រាយ

គេមាន

$$\begin{aligned}
128 &= \log_a(\log_a(\log_a 2) + \log_a 24 - 128)\\
a^{128} &= \log_a(\log_a 2) + \log_a 24 - 128\\
128 + a^{128} &= \log_a(\log_a 2) + \log_a 24\\
&= \log_a(24\log_a 2)\\
&= \log_a \log_a 2^{24}\\
a^{128+a^{128}} &= \log_a 2^{24}\\
(a^{128})(a^{a^{128}}) &= \log_a 2^{24}\\
a^{(a^{128})(a^{a^{128}})} &= 2^{24}\\
(a^{a^{128}})^{(a^{a^{128}})} &= 8^8
\end{aligned}$$

គេបាន $\quad a^{(a^{128})} = 8 \Longrightarrow (a^{128})^{(a^{128})} = 8^{128} = 64^{64}$ (លើកអង្គទាំងពីរជាស្វ័យគុណ 128)

នាំអោយ $\quad a^{128} = 64 = 2^6 \Longleftrightarrow a = 2^{\frac{6}{128}} = 2^{\frac{3}{64}}$

តែ $\quad \log_a(y) = \frac{\log_2(y)}{\log_2 a} = \frac{64}{3}\log_2(y) \quad$ (ព្រោះ$a = 2^{3/64}$)

គេបាន

$$256 = \log_a(\log_a(x)) = \frac{64}{3}\log_2(\frac{64}{3}\log_2(x))$$
$$2^{12} = \frac{64}{3}\log_2(x) \Longleftrightarrow 192 = \log_2(x) \Longleftrightarrow x = 2^{192}$$

ដូចនេះ $\boxed{x = 2^{192}}$

លំហាត់ទី ១៩. គេមានចំនួនកុំផ្លិច z ដែល $z \neq 0$ ។ ចូរដោះស្រាយសមីការ $2 - \frac{1}{z} = \bar{z}$ ។

ដំណោះស្រាយ

ដោះស្រាយសមីការ $2 - \frac{1}{z} = \bar{z}$

គេមាន $2 - \frac{1}{z} = \bar{z} \Longrightarrow 2z - 1 = z\bar{z} = |z|^2 \quad$ (ព្រោះ $\; z\bar{z} = |z|^2$)

នាំឱ្យ $2z = |z|^2 + 1 \quad (1)$ ដោយ $|z|^2 + 1 \in \mathbb{R}_+ \Longrightarrow z \in \mathbb{R}_+$

ដោយ $z \in \mathbb{R}_+ \Longrightarrow |z| = z$

តាម (1) គេបាន $2z = z^2 + 1 \Longleftrightarrow z^2 - 2z + 1 = 0 \Longleftrightarrow (z-1)^2 = 0 \Longleftrightarrow z = 1$

ដូចនេះ $\boxed{\text{សមីការមានចម្លើយ } z = 1}$

លំហាត់ទី ២០. បង្ហាញថា បើផលគុណនៃ $z_1 z_2$ ជាចំនួនពិតខុសពីសូន្យ នោះមានចំនួនពិត α មួយដែល $z_1 = \alpha\bar{z_2}$ ។

ដំណោះស្រាយ

បើផលគុណនៃ $z_1 z_2 \neq 0$ នោះ $z_1 \neq 0 \wedge z_2 \neq 0$

គេមាន $z_1 z_2$ ជាចំនួនពិត នោះ $z_1 z_2 = a$ ដែល $a \in \mathbb{R},\ a \neq 0$

គេបាន $z_1 = \frac{a}{z_2} = \frac{a\bar{z_2}}{z_2\bar{z_2}} = \frac{a}{|z_2|^2} \times \bar{z_2}$

ដោយ $\frac{a}{|z|^2} \in \mathbb{R}$ តាង $\alpha = \frac{a}{|z|^2} \in \mathbb{R},\ \alpha \neq 0$

គេបាន $z_1 = \alpha\bar{z_2}$

ដូចនេះ $\boxed{z_1 = \alpha\bar{z_2}}$

លំហាត់ទី ២១. ចំពោះចំនួនកុំផ្លិច z និង w ចូរបង្ហាញថា $|z + w| \leq |z| + |w|$ ។

ដំណោះស្រាយ

គេមាន $|z+w|^2=(z+w)(\overline{z+w})=(z+w)(\overline{z}+\overline{w})$

$=z\overline{z}+z\overline{w}+w\overline{z}+w\overline{w}=|z|^2+|w|^2+z\overline{w}+w\overline{z}$

$=|z|^2+|w|^2+z\overline{w}+\overline{z\overline{w}}$ (ព្រោះ $\overline{z\overline{w}}=\overline{z}\,\overline{\overline{w}}=\overline{z}w$)

$=|z|^2+|w|^2+2Re(z\overline{w})$ ($Re(z)$ តាងឱ្យផ្នែកពិតនៃចំនួនកុំផ្លិច z និង $Re(z)=\dfrac{z+\overline{z}}{2}$)

$\leq |z|^2+|w|^2+2|z\overline{w}|$ (ព្រោះ $Re(z\overline{w})\leq |z\overline{w}|$)

$\leq |z|^2+|w|^2+2|z||\overline{w}|$

$\leq |z|^2+|w|^2+2|z||w|$ (ព្រោះ$|w|=|\overline{w}|$)

$\leq |z|^2+2|z||w|+|w|^2$

$\leq (|z|+|w|)^2$ ដោយ $|z|\geq 0,\ |w|\geq 0$ និង $|z+w|\geq 0$ គេបាន $|z+w|^2\leq (|z|+|w|)^2$

$\Longrightarrow |z+w|\leq |z|+|w|$

ដូចនេះ $\boxed{|z+w|\leq |z|+|w|}$

លំហាត់ទី ២២. បង្ហាញថា $2+i$ ជាឫសរបស់សមីការ $z^4-5z^3+3z^2+19z-30=0$ រួចរកឫសផ្សេងទៀតរបស់សមីការនេះ។

ដំណោះស្រាយ

- បើ $2+i$ ជាឫសរបស់សមីការ $z^4-5z^3+3z^2+19z-30=0$ គេបាន

  $(2+i)^4-5(2+i)^3+3(2+i)^2+19(2+i)-30$

  $=(2^4+4\cdot 2^3i+6\cdot 2^2i^2+4\cdot 2i^3+i^4)-5(8+12i+6i^2+i^3)+3(4+4i+i^2)+(38+19i)-30$

  $=(16+32i-24-8i+1)-5(8+12i-6-i)+3(4+4i-1)+8+19i$

  $=-7+24i-10-55i+9+12i+8+19i=0$

  ដូចនេះ $2+i$ ជាឫសរបស់សមីការ $z^4-5z^3+3z^2+19z-30=0$

- រកឫសផ្សេងទៀត

  គេមាន $2+i$ ជាឫសរបស់សមីការ $z^4-5z^3+3z^2+19z-30=0$ (1)

  នាំឱ្យ $2-i$ ក៏ជាឫសរបស់សមីការ (1) ដែរ

  ដោយ $(2+i)+(2-i)=4$ និង $(2+i)(2-i)=5$ នោះ $2-i$ និង $2-i$ ជាឫសរបស់សមីការ $z^2-4z+5=0$

  គេមាន

  $z^4-5z^3+3z^2+19z-30$

  $=(z^4-4z^3+5z^2)+(4z^3-5z^2)-5z^3+3z^2+19z-30$

  $=z^2(z^2-4z+5)-z^3-2z^2+19z-30$

  $=z^2(z^2-4z+5)-(z^3-4z^2+5z)+(-4z^2+5z)-2z^2+19z-30$

$= z^2(z^2-4z+5) - z(z^2-4z+5) - 6z^2 + 24z - 30$

$= z^2(z^2-4z+5) - z(z^2-4z+5) - 6(z^2-4z+5)$

$= (z^2-4z+5)(z^2-z-6)$

នោះគេបាន $z^4 - 5z^3 + 3z^2 + 19z - 30 = 0 \iff (z^2-4z+5)(z^2-z-6) = 0$

នាំឱ្យ $z^2 - 4z + 5 = 0$ ឬ $z^2 - z - 6 = 0$

$-$ បើ $z^2 - 4z + 5 = 0 \iff z = 2 + i \vee z = 2 - i$

$-$ បើ $z^2 - z - 6 = 0 \iff z = -2 \vee z = 3$

ដូចនេះ $\boxed{\text{ឫសផ្សេងទៀតគឺ } -2,\ 3,\ 2-i}$

លំហាត់ទី ២៣. បង្ហាញថា $x^4 + 4 = (x-1-i)(x-1+i)(x+1+i)(x+1-i)$ ។

ដំណោះស្រាយ

គេមាន $(x-1-i)(x-1+i)(x+1+i)(x+1-i)$

$= [x-(1+i)]\,[x-(1-i)]\,[x+(1+i)]\,[x+(1-i)]$

$= \left[x^2-(1+i)^2\right]\left[x^2-(1-i)^2\right]$

$= \left[x^2-(1+2i+i^2)\right]\left[x^2-(1-2i+i^2)\right]$

$= (x^2-2i)(x^2+2i)$

$= x^4 - 4i^2$

$= x^4 + 4$

ដូចនេះ $\boxed{x^4 + 4 = (x-1-i)(x-1+i)(x+1+i)(x+1-i)}$

លំហាត់ទី ២៤. ដោះស្រាយសមីការ $(2+i)x^2 - (5-i)x + (2-2i) = 0$ ។

ដំណោះស្រាយ

ដោះស្រាយសមីការ $(2+i)x^2 - (5-i)x + (2-2i) = 0$

តាម $\Delta = (5-i)^2 - 4(2+i)(2-2i) = -2i = (1-i)^2$

គេបាន $x = \dfrac{5-i+1-i}{2(2+i)} = 1 - i$ ឬ $x = \dfrac{5-i-1+i}{2(2+i)} = \dfrac{4}{5} - \dfrac{2}{5}i$

ដូចនេះ $\boxed{\text{សមីការមានឫស } x = 1 - i \vee x = \dfrac{4}{5} - \dfrac{2}{5}i}$

លំហាត់ទី ២៥. រកគ្រប់ចំនួនកុំផ្លិច $z \neq 0$ ដែល $z + \dfrac{1}{z} \in \mathbb{R}$ ។

ដំណោះស្រាយ

តាង $z = x + iy$ គេបាន

$$\begin{aligned} z + \frac{1}{z} &= x + iy + \frac{1}{x+iy} \\ &= x + iy + \frac{x-iy}{(x+iy)(x-iy)} \\ &= x + iy + \frac{x-iy}{x^2+y^2} \\ &= \left(x + \frac{x}{x^2+y^2}\right) + i\left(y - \frac{y}{x^2+y^2}\right) \quad (1) \end{aligned}$$

គេបាន $z + \dfrac{1}{z} \in \mathbb{R}$ លុះត្រាតែ $y - \dfrac{y}{x^2+y^2} = 0 \Longrightarrow y = 0 \vee x^2 + y^2 = 1$

− បើ $y = 0$ គេបាន $z = x,\ x \neq 0$ នាំឱ្យ $z + \dfrac{1}{z} = x + \dfrac{1}{x} \in \mathbb{R}$
  នោះ $z + \dfrac{1}{z} \in \mathbb{R}$ លុះត្រាតែ $z \in \mathbb{R}$

− បើ $x^2 + y^2 = 1$ តាម (1) គេបាន $z + \dfrac{1}{z} = x + x = 2x \in \mathbb{R}$
  នោះ $z + \dfrac{1}{z} \in \mathbb{R}$ លុះត្រាតែ $z = x + iy$ ហើយផ្ទៀងផ្ទាត់ $x^2 + y^2 = 1$

ដូចនេះ $\boxed{z \in \mathbb{R} \vee z = x + iy \text{ ដែល } x^2 + y^2 = 1}$

លំហាត់ទី ២៦. បង្ហាញថា $z = \left(\dfrac{19+7i}{9-i}\right)^{2019} + \left(\dfrac{20+5i}{7+6i}\right)^{2019} + 19012019$ ជាចំនួនពិត។

ដំណោះស្រាយ

បង្ហាញថា z ជាចំនួនពិត

z ជាចំនួនពិតលុះត្រាតែ $z = \bar{z}$

គេមាន $\dfrac{19+7i}{9-i} = \dfrac{(19+7i)(9+i)}{(9-i)(9+i)} = \dfrac{171+19i+63i-7}{9^1+1} = \dfrac{164+82i}{82} = 2+i$

$\dfrac{20+5i}{7+6i} = \dfrac{(20+5i)(7-6i)}{(7+6i)(7-6i)} = \dfrac{140-120i+35i+30}{7^2+6^2} = \dfrac{170-85i}{85} = 2-i$

$$\begin{aligned} \text{គេបាន } z &= \left(\frac{19+7i}{9-i}\right)^{2019} + \left(\frac{20+5i}{7+6i}\right)^{2019} + 19012019 \\ &= (2+i)^{2019} + (2-i)^{2019} + 19012019 \end{aligned}$$

$$\begin{aligned} \text{នាំឱ្យ } \quad \bar{z} &= \overline{(2+i)^{2019} + (2-i)^{2019} + 19012019} \\ &= \overline{(2+i)^{2019}} + \overline{(2-i)^{2019}} + 19012019 \\ &= \left(\overline{2+i}\right)^{2019} + \left(\overline{2-i}\right)^{2019} + 19012019 \end{aligned}$$

$$= (2-i)^{2019} + (2+i)^{2019} + 19012019$$
$$= (2+i)^{2019} + (2-i)^{2019} + 19012019 = z$$

ដូចនេះ $\boxed{z \text{ ជាចំនួនពិត}}$

លំហាត់ទី ២៧. គេឲ្យ $\tan A$ និង $\tan B$ ជាឫសនៃសមីការ $x^2 + px + q = 0$ ។ ចូររកតម្លៃនៃ:
$\sin^2(A+B) + p\sin(A+B)\cos(A+B) + q\cos^2(A+B)$ ។

ដំណោះស្រាយ

គេមាន $\tan A$ និង $\tan B$ ជាឫសនៃសមីការ $x^2 + px + q = 0$

នាំឲ្យ $\tan A + \tan B = -p$ និង $\tan A \tan B = q$

តាមរូបមន្ត $\tan(A+B) = \dfrac{\tan A + \tan B}{1 - \tan A \tan B} = \dfrac{-p}{1-q} = \dfrac{p}{q-1}$

គេមាន $\sin^2(A+B) + p\sin(A+B)\cos(A+B) + q\cos^2(A+B)$

$$= \cos^2(A+B)\left[\tan^2(A+B) + p\tan(A+B) + q\right]$$
$$= \frac{1}{\tan^2(A+B)+1} \times \left[\tan^2(A+B) + p\tan(A+B) + q\right]$$
តាមលក្ខណៈ $\displaystyle\int_a^b f(x)dx=\int_a^b f(a+b-x)dx$

តាង $f(t)=\dfrac{\sin t}{\sin t+\sin(\ln 6-t)}$

$\Longrightarrow f(\ln 3+\ln 2-t)=f(\ln 6-t)=\dfrac{\sin(\ln 6-t)}{\sin(\ln 6-t)+\sin t}$

គេបាន $2I=\displaystyle\int_{\ln 2}^{\ln 3}f(t)dt=\int_{\ln 2}^{\ln 3}f(\ln 6-t)dt=\int_{\ln 2}^{\ln 3}\frac{\sin(\ln 6-t)}{\sin(\ln 6-t)+\sin t}dt \qquad (2)$

យក $(1)+(2)$ គេបាន $4I=\displaystyle\int_{\ln 2}^{\ln 3}\frac{\sin t}{\sin t+\sin(\ln 6-t)}dt+\int_{\ln 2}^{\ln 3}\frac{\sin(\ln 6-t)}{\sin(\ln 6-t)+\sin t}dt$

$$=\int_{\ln 2}^{\ln 3}\frac{\sin t+\sin(\ln 6-t)}{\sin t+\sin(\ln 6-t)}dt$$

$$=\int_{\ln 2}^{\ln 3}1dt=\Big[t\Big]_{\ln 2}^{\ln 3}=\ln 3-\ln 2=\ln\frac{3}{2}$$

គេបាន $4I=\ln\dfrac{3}{2}\Longleftrightarrow I=\dfrac{1}{4}\ln\dfrac{3}{2}$

ដូចនេះ $\boxed{I=\displaystyle\int_{\sqrt{\ln 2}}^{\sqrt{\ln 3}}\frac{x\sin x^2}{\sin x^2+\sin(\ln 6-x^2)}dx=\frac{1}{4}\ln\frac{3}{2}}$

លំហាត់ទី ១០១. គេឱ្យ A ជាម៉ាទ្រីសការេ និងផ្ទៀងផ្ទាត់ $A^2=I$ ។ រកម៉ាទ្រីសច្រាសនៃ A ។

ដំណោះស្រាយ

គេមាន $A^2=I\Longleftrightarrow A^{-1}A^2=A^{-1}I\Longleftrightarrow A^{-1}I=A^{-1}\Longleftrightarrow A^{-1}=A$

ដូចនេះ $\boxed{A^{-1}=A}$

លំហាត់ទី ១០២. គេមានម៉ាទ្រីស $A = \begin{bmatrix} 1 & \sin\theta & 1 \\ -\sin\theta & 1 & \sin\theta \\ -1 & -\sin\theta & 1 \end{bmatrix}$ ។

រកវ៉ង់នៃ $|A|$ ។

ដំណោះស្រាយ

គេមាន $A = \begin{vmatrix} 1 & \sin\theta & 1 \\ -\sin\theta & 1 & \sin\theta \\ -1 & -\sin\theta & 1 \end{vmatrix}$

$$= 1 - \sin^2\theta + \sin^2\theta + 1 + \sin^2\theta + \sin^2\theta$$

$$= 2 + 2\sin^2\theta = 2(1 + \sin^2\theta)$$

ដោយ $0 \le \sin^2\theta \le 1 \Longrightarrow 1 \le 1 + \sin^2\theta \le 2 \Longrightarrow 2 \le 2(1+\sin^2\theta) \le 4$

$\Longleftrightarrow 2 \le |A| \le 4$

ដូចនេះ $\boxed{2 \le |A| \le 4}$

លំហាត់ទី ១០៣. គេឱ្យ $\vec{a}$ និង $\vec{b}$ ជាពីរវ៉ិចទ័រឯកតា និងមិនកូលីនេអ៊ែរគ្នា។ បើ $\vec{u} = \vec{a} - (\vec{a}\cdot\vec{b})\vec{b}$ និង $\vec{v} = \vec{a}\times\vec{b}$

បង្ហាញថា $|\vec{v}| = |\vec{u}| + |\vec{u}\cdot\vec{b}|$ ។

ដំណោះស្រាយ

គេមាន $\vec{v} = \vec{a}\times\vec{b} \Longrightarrow |\vec{v}| = |\vec{a}\times\vec{b}| = |\vec{a}||\vec{b}|\sin\theta \quad (1)$

ដែល θ ជាមុំផ្គុំឡើងដោយ $\vec{a}$ និង $\vec{b}$ និង $0 < \theta < \pi$ ។

ដោយ$\vec{a}$ និង $\vec{b}$ ជាវ៉ិចទ័រឯកតា គេបាន $|\vec{a}| = |\vec{b}| = 1$

តាម (1) គេបាន $|\vec{v}| = \sin\theta \qquad (2)$

គេមាន $\vec{u} = \vec{a} - (\vec{a}\cdot\vec{b})\vec{b} = \vec{a} - \left(|\vec{a}||\vec{b}|\cos\theta\right)\vec{b} = \vec{a} - (1\cdot 1\cdot\cos\theta)\vec{b} = \vec{a} - \vec{b}\cos\theta$

$\Longrightarrow |\vec{u}|^2 = |\vec{a} - \vec{b}\cos\theta|^2 = (\vec{a} - \vec{b}\cos\theta)(\vec{a} - \vec{b}\cos\theta)$

$$= \vec{a}\cdot\vec{a} - 2\vec{a}\cdot\vec{b}\cos\theta + \vec{b}\cdot\vec{b} = |\vec{a}|^2 - 2(\vec{a}\cdot\vec{b})\cos\theta + |\vec{b}|^2\cos^2\theta$$

$$= 1 - 2(\cos\theta)\cos\theta + \cos^2\theta = 1 - \cos^2\theta = \sin^2\theta$$

នាំឱ្យ $|\vec{u}| = \sin\theta \qquad (3)$

តាម (2) និង (3) គេបាន $|\vec{v}| = |\vec{u}| \quad (4)$

ម្យ៉ាងទៀត $\vec{u}\cdot\vec{b} = \vec{a}\cdot\vec{b} - (\vec{a}\cdot\vec{b})\vec{b}\cdot\vec{b} = \vec{a}\cdot\vec{b} - (\vec{a}\cdot\vec{b})|\vec{b}|^2 = \vec{a}\cdot\vec{b} - \vec{a}\cdot\vec{b} = 0 \Longrightarrow |\vec{u}\cdot\vec{b}| = 0 \quad (5)$

តាម (4) និង (5) គេបាន $|\vec{v}| = |\vec{u}| + |\vec{u}\cdot\vec{b}|$

ដូចនេះ $\boxed{|\vec{v}| = |\vec{u}| + |\vec{u}\cdot\vec{b}|}$

លំហាត់ទី ១០៤. គណនាផលបូក $\dfrac{1}{1!(n-1)!}+\dfrac{1}{3!(n-3)!}+\dfrac{1}{5!(n-5)!}+\cdots+\dfrac{1}{(n-1)!1!}$

ដំណោះស្រាយ

តាង $S=\dfrac{1}{1!(n-1)!}+\dfrac{1}{3!(n-3)!}+\dfrac{1}{5!(n-5)!}+\cdots+\dfrac{1}{(n-1)!1!}$

គេបាន $n!\times S=\dfrac{n!}{1!(n-1)!}+\dfrac{n!}{3!(n-3)!}+\dfrac{n!}{5!(n-5)!}+\cdots+\dfrac{n!}{(n-1)!1!}$

$=C(n,1)+C(n,3)+C(n,5)+\cdots+C(n,n)$

តាង $P=C(n,0)+C(n,2)+C(n,4)+\cdots$

និង $L=C(n,1)+C(n,3)+C(n,5)+\cdots$

គេបាន $P+L=C(n,0)+C(n,1)+C(n,2)+C(n,3)+\cdots=(1+1)^n=2^n \quad (1)$

ហើយ $P-L=C(n,0)-C(n,1)+C(n,2)-C(n,3)+\cdots=(1-1)^n=0 \quad (2)$

តាម (1) និង (2) គេបាន $P=L=2^{n-1}$

នាំឱ្យ គេបាន $n!\times S=2^{n-1}\iff S=\dfrac{2^{n-1}}{n!}$

ដូចនេះ $\boxed{\dfrac{1}{1!(n-1)!}+\dfrac{1}{3!(n-3)!}+\dfrac{1}{5!(n-5)!}+\cdots+\dfrac{1}{(n-1)!1!}=\dfrac{2^{n-1}}{n!}}$

លំហាត់ទី ១០៥. គេមាន $\sin^3 x\sin 3x=\sum_{m=0}^{n}C_m\cos(mx)$ ដែល $C_0,C_1,\cdots,C_n$ ជាចំនួនពិត និង $C_n\neq 0$ ។ រកតម្លៃនៃ n ។

ដំណោះស្រាយ

គេមាន $\sin 3x=3\sin x-4\sin^3 x\Longrightarrow \sin^3 x=\dfrac{1}{4}(3\sin x-\sin 3x)$

គេបាន $\sin^3 x\sin 3x=\dfrac{1}{4}(3\sin x-\sin 3x)\sin 3x=\dfrac{1}{4}\left(3\sin x\sin 3x-\sin^2 3x\right)$

$$=\frac{1}{4}\left[\frac{3}{2}(\cos 2x-\cos 4x)-\frac{1-\cos 6x}{2}\right]$$

$$=\frac{1}{8}(3\cos 2x-3\cos 4x-1+\cos 6x)$$

$$=-\frac{1}{8}+\frac{3}{8}\cos 2x-\frac{3}{8}\cos 4x+\frac{1}{8}\cos 6x$$

$$=-\frac{1}{8}\cos 0+0\cdot\cos x+\frac{3}{8}\cos 2x+0\cdot\cos 3x-\frac{3}{8}\cos 4x+0\cdot\cos 5x+\frac{1}{8}\cos 6x$$

$$=\sum_{m=0}^{6}C_m\cos(mx)$$

ដែល $C_0=-\dfrac{1}{8},C_1=0,C_2=\dfrac{3}{8},C_3=0,C_4=-\dfrac{3}{8},C_5=0,C_6=\dfrac{1}{8}$

ដូចនេះ $\boxed{n=6}$

លំហាត់ទី ១០៦. គណនាតម្លៃនៃកន្សោម $\sin\frac{\pi}{14}\sin\frac{3\pi}{14}\sin\frac{5\pi}{14}\sin\frac{7\pi}{14}\sin\frac{9\pi}{14}\sin\frac{13\pi}{14}$ ។

ដំណោះស្រាយ

តាង $P = \sin\frac{\pi}{14}\sin\frac{3\pi}{14}\sin\frac{5\pi}{14}\sin\frac{7\pi}{14}\sin\frac{9\pi}{14}\sin\frac{13\pi}{14}$

$$= \sin\frac{\pi}{14}\sin\frac{3\pi}{14}\sin\frac{5\pi}{14}\sin\frac{\pi}{2}\sin\left(\pi-\frac{5\pi}{14}\right)\sin\left(\pi-\frac{3\pi}{14}\right)\sin\left(\pi-\frac{\pi}{14}\right)$$

$$= \sin\frac{\pi}{14}\sin\frac{3\pi}{14}\sin\frac{5\pi}{14}\times 1\times\sin\frac{5\pi}{14}\sin\frac{3\pi}{14}\sin\frac{\pi}{14}$$

$$= \left(\sin\frac{\pi}{14}\sin\frac{3\pi}{14}\sin\frac{5\pi}{14}\right)^2$$

សម្គាល់

$\sin(\pi-\theta) = \sin\theta$

$\cos\left(\frac{\pi}{2}-\alpha\right) = \sin\alpha$

$$= \left[\cos\left(\frac{\pi}{2}-\frac{\pi}{14}\right)\cos\left(\frac{\pi}{2}-\frac{3\pi}{14}\right)\cos\left(\frac{\pi}{2}-\frac{5\pi}{14}\right)\right]^2$$

$$= \left(\cos\frac{3\pi}{7}\cos\frac{2\pi}{7}\cos\frac{\pi}{7}\right)^2 = \left(\cos\frac{\pi}{7}\cos\frac{2\pi}{7}\cos\frac{3\pi}{7}\right)^2$$

$$= \left(\frac{\sin\frac{2\pi}{7}}{2\sin\frac{\pi}{7}}\times\frac{\sin\frac{4\pi}{7}}{2\sin\frac{2\pi}{7}}\times\frac{\sin\frac{6\pi}{7}}{2\sin\frac{3\pi}{7}}\right)^2 = \left(\frac{\sin\frac{4\pi}{7}\sin\frac{6\pi}{7}}{8\sin\frac{\pi}{7}\sin\frac{3\pi}{7}}\right)^2$$

សម្គាល់

គេមាន $\sin 2a = 2\sin a\cos a$

$\Longleftrightarrow \cos a = \frac{\sin 2a}{2\sin a}$

$$= \frac{1}{64}\left[\frac{\sin\frac{4\pi}{7}\sin\left(\pi-\frac{\pi}{7}\right)}{\sin\frac{\pi}{7}\sin\left(\pi-\frac{4\pi}{7}\right)}\right]^2 = \frac{1}{64}\left(\frac{\sin\frac{4\pi}{7}\sin\frac{\pi}{7}}{\sin\frac{\pi}{7}\sin\frac{4\pi}{7}}\right)^2 = \frac{1}{64}$$

ដូចនេះ $\boxed{\sin\frac{\pi}{14}\sin\frac{3\pi}{14}\sin\frac{5\pi}{14}\sin\frac{7\pi}{14}\sin\frac{9\pi}{14}\sin\frac{13\pi}{14} = \frac{1}{64}}$

លំហាត់ទី ១០៧. គណនាតម្លៃនៃកន្សោម $L = \sin\frac{\pi}{18}\sin\frac{5\pi}{18}\sin\frac{7\pi}{18}$ ។

ដំណោះស្រាយ

គេមាន $L = \sin\frac{\pi}{18}\sin\frac{5\pi}{18}\sin\frac{7\pi}{18}$

$$= \cos\left(\frac{\pi}{2}-\frac{\pi}{18}\right)\cos\left(\frac{\pi}{2}-\frac{5\pi}{18}\right)\cos\left(\frac{\pi}{2}-\frac{7\pi}{18}\right)$$

$$= \cos\frac{4\pi}{9}\cos\frac{2\pi}{9}\cos\frac{\pi}{9} = \cos\frac{\pi}{9}\cos\frac{2\pi}{9}\cos\frac{4\pi}{9}$$

$$= \frac{\sin\frac{2\pi}{9}}{2\sin\frac{\pi}{9}}\times\frac{\sin\frac{4\pi}{9}}{2\sin\frac{2\pi}{9}}\times\frac{\sin\frac{8\pi}{9}}{2\sin\frac{4\pi}{9}} = \frac{\sin\frac{8\pi}{9}}{8\sin\frac{\pi}{9}}$$

$$= \frac{\sin\left(\pi-\frac{\pi}{9}\right)}{8\sin\frac{\pi}{9}} = \frac{\sin\frac{\pi}{9}}{8\sin\frac{\pi}{9}} = \frac{1}{8}$$

ដូចនេះ $\boxed{L = \sin\frac{\pi}{18}\sin\frac{5\pi}{18}\sin\frac{7\pi}{18} = \frac{1}{8}}$

លំហាត់ទី ១០៨. គេឱ្យ $A > 0, B > 0$ និង $A + B = \frac{\pi}{3}$ ។

រកតម្លៃអតិបរមានៃកន្សោម $y = \tan A\tan B$ ។

ដំណោះស្រាយ

គេមាន $A + B = \frac{\pi}{3} \Longrightarrow \tan(A+B) = \tan\frac{\pi}{3} = \sqrt{3}$

ម្យ៉ាងទៀត $\tan(A+B) = \frac{\tan A + \tan B}{1 - \tan A\tan B} = \frac{\tan A + \frac{y}{\tan A}}{1-y}$

$\Longleftrightarrow \sqrt{3} = \frac{\tan A + \frac{y}{\tan A}}{1-y} = \frac{\tan^2 A + y}{(1-y)\tan A}$

គេបាន $\tan^2 A + y = \sqrt{3}(1-y)\tan A$

$\Longrightarrow \tan^2 A - \sqrt{3}(1-y)\tan A + y = 0 \qquad (1)$

តាម $\Delta = 3(1-y)^2 - 4y = 3 - 6y + 3y^2 - 4y = 3y^2 - 10y + 3$

ចំពោះគ្រប់តម្លៃនៃ $\tan A$ សមីការ (1) មានឫសជាចំនួនពិត នាំឱ្យ $\Delta \geq 0$ ។

គេបាន $3y^2 - 10y + 3 \geq 0 \Longleftrightarrow (y-3)\left(3y-1\right) \geq 0 \Longleftrightarrow y \leq \frac{1}{3} \ \vee \ y \geq 3$

តែ $A > 0, B > 0$ និង $A + B = \frac{\pi}{3} \Longrightarrow 0 < A, B < \frac{\pi}{3} \Longrightarrow 0 < y = \tan A\tan B < 3$

គេបាន $y = \tan A\tan B \leq \frac{1}{3}$

ដូចនេះ $\boxed{\text{តម្លៃអតិបរមានៃកន្សោម } y = \tan A\tan B \text{ គឺ } \frac{1}{3}}$

លំហាត់ទី ១០៩. ដោះស្រាយសមីការ $\cos^7 x + \sin^4 x = 1$ លើចន្លោះ $(-\pi, \pi)$ ។

ដំណោះស្រាយ

គេមាន $\cos^7 x + \sin^4 x = 1 \Longleftrightarrow \cos^7 x = 1 - \sin^4 x$

នាំឱ្យ $\cos^7 x = (1 - \sin^2 x)(1 + \sin^2 x) = \cos^2 x(1 + \sin^2 x)$

គេបាន $\cos^7 x - \cos^2 x(1 + \sin^2 x) = 0 \Longleftrightarrow \cos^2 x(\cos^5 x - 1 - \sin^2 x) = 0$

- បើ $\cos^2 x = 0 \Longleftrightarrow \cos x = 0 \Longleftrightarrow x = -\dfrac{\pi}{2} \ \vee\ x = \dfrac{\pi}{2}$
- បើ $\cos^5 x - 1 - \sin^2 x = 0 \Longleftrightarrow \cos^5 x - \sin^2 x = 1 \quad (1)$

  គេដឹងថាតម្លៃអតិបរមានៃ $\sin x$ និង $\cos x$ គឺស្មើនឹង 1 នោះសមីការ (1) មានឫស កាលណា $\cos x = 1$ និង $\sin x = 0$

  គេបាន $x = 0$

ដូចនេះ $\boxed{\text{សមីការមានឫស } x = -\dfrac{\pi}{2} \ \vee\ x = 0 \ \vee\ x = \dfrac{\pi}{2}}$

លំហាត់ទី ១១០. គេឱ្យ $A = \sin^2 x + \cos^4 x$ ។ ចំពោះគ្រប់តម្លៃនៃចំនួនពិត x រកវ៉ង់នៃ A ។

ដំណោះស្រាយ

គេមាន $A = \sin^2 x + \cos^4 x = \sin^2 x + (1 - \sin^2 x)^2 = \sin^2 x + 1 - 2\sin^2 x + \sin^4 x$

$$= \sin^4 x - \sin^2 x + 1 = \left(\sin^2 x - \frac{1}{2}\right)^2 + \frac{3}{4}$$

ចំពោះ $\forall x \in \mathbb{R},\ -1 \le \sin x \le 1 \Longleftrightarrow 0 \le \sin^2 x \le 1$

$$-\frac{1}{2} \le \sin^2 x - \frac{1}{2} \le \frac{1}{2} \Longleftrightarrow 0 \le \left(\sin^2 x - \frac{1}{2}\right)^2 \le \frac{1}{4}$$

$$\frac{3}{4} \le \left(\sin^2 x - \frac{1}{2}\right)^2 + \frac{3}{4} \le 1 \Longleftrightarrow \frac{3}{4} \le A \le 1$$

ដូចនេះ $\boxed{\dfrac{3}{4} \le A \le 1}$

លំហាត់ទី ១១១. ដោះស្រាយសមីការ $\sin x - 3\sin 2x + \sin 3x = \cos x - 3\cos 2x + \cos 3x$

ដំណោះស្រាយ

គេមាន $\sin x - 3\sin 2x + \sin 3x = \cos x - 3\cos 2x + \cos 3x$

$$(\sin x + \sin 3x) - 3\sin 2x = (\cos x + \cos 3x) - 3\cos 2x$$

សម្គាល់

$$\sin p + \sin q = 2\sin\frac{p+q}{2}\cos\frac{p-q}{2}$$

$$\cos p + \cos q = 2\cos\frac{p+q}{2}\cos\frac{p-q}{2}$$

$$2\sin 2x\cos x - 3\sin 2x = 2\cos 2x\cos x - 3\cos 2x$$

$$\sin 2x(2\cos x - 3) = \cos 2x(2\cos x - 3)$$

$\Longrightarrow \sin 2x = \cos 2x$ ព្រោះ $2\cos x - 3 = 2\left(\cos x - \frac{3}{2}\right) \neq 0$

គេបាន $\sin 2x = \cos 2x \Longrightarrow \tan 2x = 1 \Longrightarrow 2x = \frac{\pi}{4} + k\pi \Longrightarrow x = \frac{\pi}{8} + \frac{k\pi}{2}, k \in \mathbb{Z}$

ដូចនេះ $\boxed{\text{សមីការមានឫស } x = \frac{\pi}{8} + \frac{k\pi}{2}, k \in \mathbb{Z}}$

លំហាត់ទី ១១២. រកតម្លៃអតិបរមានៃ $\cos x_1 \cos x_2 \cos x_3 \cdots \cos x_n$ បើគេដឹងថា $0 \leq x_1, x_2, x_3, \ldots, x_n \leq \frac{\pi}{2}$ និង $\cot x_1 \cot x_2 \cot x_3 \cdots \cot x_n = 1$ ។

ដំណោះស្រាយ

គេមាន $\cot x_1 \cot x_2 \cot x_3 \cdots \cot x_n = 1$

$\Longrightarrow \frac{\cos x_1}{\sin x_1} \times \frac{\cos x_2}{\sin x_2} \times \frac{\cos x_3}{\sin x_3} \times \cdots \times \frac{\cos x_n}{\sin x_n} = 1$

$\Longrightarrow \cos x_1 \cos x_2 \cos x_3 = \sin x_1 \sin x_2 \sin x_3 \cdots \sin x_n$

តាង $y = \cos x_1 \cos x_2 \cos x_3 \cdots \cos x_n$

គេបាន $y^2 = \cos^2 x_1 \cos^2 x_2 \cos^2 x_3 \cdots \cos^2 x_n$

$$= (\cos x_1 \cos x_2 \cos x_3 \cdots \cos x_n)(\cos x_1 \cos x_2 \cos x_3 \cdots \cos x_n)$$

$$= (\cos x_1 \cos x_2 \cos x_3 \cdots \cos x_n)(\sin x_1 \sin x_2 \sin x_3 \cdots \sin x_n)$$

$$= (\sin x_1 \cos x_1)(\sin x_2 \cos x_2)(\sin x_3 \cos x_3)\cdots(\sin x_n \cos x_n)$$

$$= \frac{\sin 2x_1}{2} \times \frac{\sin 2x_2}{2} \times \frac{\sin 2x_3}{2} \times \cdots \times \frac{\sin 2x_n}{2}$$

$$= \frac{1}{2^n}\sin 2x_1 \sin 2x_2 \sin 2x_3 \cdots \sin 2x_n$$

តែ $0 \leq x_1, x_2, x_3, \ldots, x_n \leq \frac{\pi}{2} \Longrightarrow 0 \leq 2x_1, 2x_2, 2x_3, \ldots, 2x_n \leq \pi$

$\Longrightarrow 0 \leq \sin 2x_1, \sin 2x_2, \sin 2x_3, \ldots, \sin 2x_n \leq 1$

គេបាន $y^2 \leq \frac{1}{2^n} \Longrightarrow y \leq \frac{1}{2^{\frac{n}{2}}}$

ដូចនេះ $\boxed{\text{តម្លៃអតិបរមានៃ } \cos x_1 \cos x_2 \cos x_3 \cdots \cos x_n \text{ គឺ } \frac{1}{2^{\frac{n}{2}}}}$

លំហាត់ទី ១១៣. ប្រៀបធៀប $t_1 = (\tan\theta)^{\tan\theta}, t_2 = (\tan\theta)^{\cot\theta}, t_3 = (\cot\theta)^{\tan\theta}$ និង $t_4 = (\cot\theta)^{\cot\theta}$ ចំពោះ $\theta \in \left(0, \frac{\pi}{4}\right)$ ។

ដំណោះស្រាយ

ចំពោះ $\theta \in \left(0, \frac{\pi}{4}\right)$ នាំឱ្យ $0 < \tan\theta < 1 < \cot\theta$ គេបាន $t_1 < t_2$ និង $t_3 < t_4$

ម្យ៉ាងទៀត $0 < \tan\theta < 1, \cot\theta > 1 \Longrightarrow 0 < (\tan\theta)^{\cot\theta} < 1$ និង $(\cot\theta)^{\tan\theta} > 1$

គេបាន $t_2 < t_3$

ដូចនេះ $\boxed{t_1 < t_2 < t_3 < t_4}$

លំហាត់ទី ១១៤. គណនា $S = \sum_{k=1}^{13} \frac{1}{\sin\left(\frac{\pi}{4} + \frac{(k-1)\pi}{6}\right)\sin\left(\frac{\pi}{4} + \frac{k\pi}{6}\right)}$ ។

ដំណោះស្រាយ

គណនា $S = \sum_{k=1}^{13} \frac{1}{\sin\left(\frac{\pi}{4} + \frac{(k-1)\pi}{6}\right)\sin\left(\frac{\pi}{4} + \frac{k\pi}{6}\right)}$

$$= \frac{1}{\sin\frac{\pi}{6}} \sum_{k=1}^{13} \frac{\sin\left[\left(\frac{\pi}{4} + \frac{k\pi}{6}\right) - \left(\frac{\pi}{4} + \frac{(k-1)\pi}{6}\right)\right]}{\sin\left(\frac{\pi}{4} + \frac{(k-1)\pi}{6}\right)\sin\left(\frac{\pi}{4} + \frac{k\pi}{6}\right)}$$

សម្គាល់

$\sin(\alpha - \beta) = \sin\alpha\cos\beta - \sin\beta\cos\alpha$

$$= \frac{1}{\sin\frac{\pi}{6}} \sum_{k=1}^{13} \left[\cot\left(\frac{\pi}{4} + \frac{(k-1)\pi}{6}\right) - \cot\left(\frac{\pi}{4} + \frac{k\pi}{6}\right)\right]$$

$$= 2\left[\cot\frac{\pi}{4} - \cot\left(\frac{\pi}{4} + \frac{13\pi}{6}\right)\right] = 2\left(\cot\frac{\pi}{4} - \cot\frac{29\pi}{12}\right)$$

$$= 2\left[1 - \cot\left(2\pi + \frac{5\pi}{12}\right)\right] = 2 - 2\cot\frac{5\pi}{12}$$

$$= 2 - 2\cot\left(\frac{\pi}{6} + \frac{\pi}{4}\right) = 2 - 2 \times \frac{\cot\frac{\pi}{6} - \cot\frac{\pi}{4}}{\cot\frac{\pi}{6} + \cot\frac{\pi}{4}}$$

$$= 2 - 2 \times \frac{\sqrt{3} - 1}{\sqrt{3} + 1} = 2 \times \frac{\sqrt{3} + 1 - \sqrt{3} + 1}{\sqrt{3} + 1} = \frac{4}{\sqrt{3} + 1}$$

$$= \frac{4(\sqrt{3} - 1)}{2} = 2(\sqrt{3} - 1)$$

ដូចនេះ $\boxed{S = 2(\sqrt{3} - 1)}$

លំហាត់ទី ១១៥. គណនា $\left(1 + \cos\frac{\pi}{8}\right)\left(1 + \cos\frac{3\pi}{8}\right)\left(1 + \cos\frac{5\pi}{8}\right)\left(1 + \cos\frac{7\pi}{8}\right)$ ។

ដំណោះស្រាយ

គណនា $\left(1+\cos\frac{\pi}{8}\right)\left(1+\cos\frac{3\pi}{8}\right)\left(1+\cos\frac{5\pi}{8}\right)\left(1+\cos\frac{7\pi}{8}\right)$

$$= \left(1+\cos\frac{\pi}{8}\right)\left(1+\cos\frac{3\pi}{8}\right)\left[1+\cos\left(\pi-\frac{3\pi}{8}\right)\right]\left[1+\cos\left(\pi\frac{\pi}{8}\right)\right]$$

$$= \left(1+\cos\frac{\pi}{8}\right)\left(1+\cos\frac{3\pi}{8}\right)\left(1-\cos\frac{3\pi}{8}\right)\left(1-\cos\frac{\pi}{8}\right)$$

$$= \left(1-\cos^2\frac{\pi}{8}\right)\left(1-\cos^2\frac{3\pi}{8}\right)$$

$$= \sin^2\frac{\pi}{8}\sin^2\frac{3\pi}{8} = \left[\sin\frac{\pi}{8}\cos\left(\frac{\pi}{2}-\frac{3\pi}{8}\right)\right]^2$$

$$= \left(\sin\frac{\pi}{8}\cos\frac{\pi}{8}\right)^2 = \left(\frac{1}{2}\sin\frac{2\pi}{8}\right)^2 = \left(\frac{1}{2}\sin\frac{\pi}{4}\right)^2$$

$$= \left(\frac{1}{2}\times\frac{\sqrt{2}}{2}\right)^2 = \frac{1}{8}$$

ដូចនេះ $\boxed{\left(1+\cos\frac{\pi}{8}\right)\left(1+\cos\frac{3\pi}{8}\right)\left(1+\cos\frac{5\pi}{8}\right)\left(1+\cos\frac{7\pi}{8}\right)\frac{1}{8}}$

លំហាត់ទី ១១៦. សម្រួលកន្សោម

$3\left[\sin^4\left(\frac{3\pi}{2}-\alpha\right)+\sin^4(3\pi+\alpha)\right]-2\left[\sin^6\left(\frac{\pi}{2}+\alpha\right)+\sin^6(5\pi-\alpha)\right]$ ។

ដំណោះស្រាយ

សម្រួលកន្សោម

$$3\left[\sin^4\left(\frac{3\pi}{2}-\alpha\right)+\sin^4(3\pi+\alpha)\right]-2\left[\sin^6\left(\frac{\pi}{2}+\alpha\right)+\sin^6(5\pi-\alpha)\right]$$

$$= 3\left\{\left[\sin\left(\pi+\frac{\pi}{2}-\alpha\right)\right]^4+[\sin(2\pi+\pi+\alpha)]^4\right\}$$
$$-2\left\{\left[\sin\left(\frac{\pi}{2}+\alpha\right)\right]^6+[\sin(4\pi+\pi+\alpha)]^6\right\}$$

$$= 3\left\{\left[-\sin\left(\frac{\pi}{2}-\alpha\right)\right]^4+[\sin(\pi+\alpha)]^4\right\}$$
$$-2\left\{[\cos(\alpha)]^6+[\sin(\pi+\alpha)]^6\right\}$$

$$= 3\left[(-\cos\alpha)^4+(-\sin\alpha)^4\right]-2\left[\cos^6\alpha+(-\sin\alpha)^6\right]$$

$$= 3(\cos^4\alpha+\sin^4\alpha)-2(\cos^6\alpha+\sin^6\alpha)$$

$$= 3(\cos^4\alpha+\sin^4\alpha)-2[(\cos^2\alpha)^3+(\sin^2\alpha)^3]$$

$$= 3(\cos^4\alpha+\sin^4\alpha)-2(\cos^2\alpha+\sin^2\alpha)(\cos^4\alpha-\cos^2\alpha\sin^2\alpha+\sin^4\alpha)$$

$$= 3(\cos^4\alpha+\sin^4\alpha)-2(\cos^4\alpha+\sin^4\alpha-\cos^2\alpha\sin^2\alpha)$$

$$= 3(\cos^4\alpha+\sin^4\alpha)-2(\cos^4\alpha+\sin^4\alpha)+2\cos^2\alpha\sin^2\alpha$$

$$= \cos^4\alpha + \sin^4\alpha + 2\cos^2\alpha\sin^2\alpha$$

$$= (\cos^2\alpha + \sin^2\alpha)^2 = 1$$

ដូចនេះ $\boxed{3\left[\sin^4\left(\frac{3\pi}{2}-\alpha\right)+\sin^4(3\pi+\alpha)\right]-2\left[\sin^6\left(\frac{\pi}{2}+\alpha\right)+\sin^6(5\pi-\alpha)\right]=1}$

លំហាត់ទី ១១៧. រកតម្លៃនៃ θ ដែល $0 \le \theta \le \frac{\pi}{2}$ ហើយផ្ទៀងផ្ទាត់

$$\begin{vmatrix} 1+\sin^2\theta & \cos^2\theta & 4\sin 4\theta \\ \sin^2\theta & 1+\cos^2\theta & 4\sin 4\theta \\ \sin^2\theta & \cos^2\theta & 1+4\sin 4\theta \end{vmatrix} = 0 \text{ ។}$$

ដំណោះស្រាយ

តាង $\Delta = \begin{vmatrix} 1+\sin^2\theta & \cos^2\theta & 4\sin 4\theta \\ \sin^2\theta & 1+\cos^2\theta & 4\sin 4\theta \\ \sin^2\theta & \cos^2\theta & 1+4\sin 4\theta \end{vmatrix}$

$$= \begin{vmatrix} 1 & 0 & -1 \\ 0 & 1 & -1 \\ \sin^2\theta & \cos^2\theta & 1+4\sin 4\theta \end{vmatrix}$$

$$= 1 + 4\sin 4\theta + 0 + 0 + \sin^2\theta + \cos^2\theta - 0$$

$$= 2 + 4\sin 4\theta$$

គេបាន $\Delta = 0 \Longleftrightarrow 2 + 4\sin 4\theta = 0$

$\Longleftrightarrow \sin 4\theta = -\frac{1}{2} = \sin\left(\pi + \frac{\pi}{6}\right) = \sin\left(2\pi - \frac{\pi}{6}\right)$

នាំឱ្យ $4\theta = \pi + \frac{\pi}{6} = \frac{7\pi}{6} \Longleftrightarrow \theta = \frac{7\pi}{24}$

ឬ $4\theta = 2\pi - \frac{\pi}{6} = \frac{11\pi}{6} \Longleftrightarrow \theta = \frac{11\pi}{24}$

ដូចនេះ $\boxed{\theta = \frac{7\pi}{24} \text{ ឬ } \theta = \frac{11\pi}{24}}$

លំហាត់ទី ១១៨. បង្ហាញថា

ក. $(\sin 12^\circ)(\sin 48^\circ)(\sin 54^\circ) = \frac{1}{8}$

ខ. $16\cos\frac{2\pi}{15}\cos\frac{4\pi}{15}\cos\frac{8\pi}{15}\cos\frac{16\pi}{15} = 1$

ដំណោះស្រាយ

ក. បង្ហាញថា $(\sin 12^\circ)(\sin 48^\circ)(\sin 54^\circ) = \dfrac{1}{8}$

គេមាន $(\sin 12^\circ)(\sin 48^\circ)(\sin 54^\circ) = (\sin 12^\circ \sin 48^\circ)\sin 54^\circ$

$$= \frac{1}{2}[\cos(48^\circ - 12^\circ) - \cos(48^\circ + 12^\circ)]\cos(90^\circ - 54^\circ)$$

$$= \frac{1}{2}[\cos 36^\circ - \cos 60^\circ]\cos 36^\circ$$

$$= \frac{1}{2}\left[\cos 36^\circ - \frac{1}{2}\right]\cos 36^\circ$$

$$= \frac{1}{2}\cos^2 36^\circ - \frac{1}{4}\cos 36^\circ \qquad (1)$$

គេមាន $2 \times 36^\circ = 72^\circ = 180^\circ - 108^\circ = 180 - 3 \times 36^\circ$

តាង $\alpha = 36^\circ$ គេបាន $\cos 2\alpha = \cos(180^\circ - 3\alpha) = -\cos 3\alpha$

គេបាន $2\cos^2\alpha - 1 = -(4\cos^3\alpha - 3\cos\alpha)$

$$4\cos^3\alpha + 2\cos^2\alpha - 3\cos\alpha - 1 = 0$$

$$4\cos^3\alpha + 4\cos^2\alpha - 2\cos^2\alpha - 2\cos\alpha - \cos\alpha - 1 = 0$$

$$4\cos^2\alpha(\cos\alpha + 1) - 2\cos\alpha(\cos\alpha + 1) - (\cos\alpha + 1) = 0$$

$$(\cos\alpha + 1)(4\cos^2\alpha - 2\cos\alpha - 1) = 0$$

តែ $\cos\alpha = \cos 36^\circ \neq -1 \Longrightarrow \cos\alpha + 1 \neq 0$

គេបាន $4\cos^2\alpha - 2\cos\alpha - 1 = 0$

តាម $\Delta' = 1 + 4 = 5 \Longrightarrow \cos\alpha = \dfrac{1 \pm \sqrt{5}}{4}$

តែ $\cos\alpha = \cos 36^\circ > 0 \Longrightarrow \cos\alpha = \dfrac{\sqrt{5}+1}{4}$

ហេតុនេះ $\cos 36^\circ = \dfrac{\sqrt{5}+1}{4}$ តាម (1) គេបាន

$$(\sin 12^\circ)(\sin 48^\circ)(\sin 54^\circ) = \frac{1}{2}\cos^2 36^\circ - \frac{1}{4}\cos 36^\circ$$

$$= \frac{1}{2}\left(\frac{\sqrt{5}+1}{4}\right)^2 - \frac{1}{4}\left(\frac{\sqrt{5}+1}{4}\right) = \frac{1}{2}\left(\frac{6+2\sqrt{5}}{16}\right) - \frac{1}{4}\left(\frac{\sqrt{5}+1}{4}\right)$$

$$= \frac{3+\sqrt{5}}{16} - \frac{\sqrt{5}+1}{16} = \frac{2}{16} = \frac{1}{8} \qquad \text{ពិត}$$

ដូចនេះ $\boxed{(\sin 12^\circ)(\sin 48^\circ)(\sin 54^\circ) = \dfrac{1}{8}}$

ខ. បង្ហាញថា $16\cos\dfrac{2\pi}{15}\cos\dfrac{4\pi}{15}\cos\dfrac{8\pi}{15}\cos\dfrac{16\pi}{15} = 1$

តាង $L = 16\cos\dfrac{2\pi}{15}\cos\dfrac{4\pi}{15}\cos\dfrac{8\pi}{15}\cos\dfrac{16\pi}{15}$

តាម $\sin 2a = 2\sin a\cos a \Longrightarrow \cos a = \dfrac{\sin 2a}{a}$

គេបាន $L = 16 \times \dfrac{\sin\frac{4\pi}{15}}{2\sin\frac{2\pi}{15}} \times \dfrac{\sin\frac{8\pi}{15}}{2\sin\frac{4\pi}{15}} \times \dfrac{\sin\frac{16\pi}{15}}{2\sin\frac{8\pi}{15}} \times \dfrac{\sin\frac{32\pi}{15}}{2\sin\frac{16\pi}{15}}$

$$= 16 \times \frac{\sin\frac{32\pi}{15}}{16\sin\frac{2\pi}{15}} = \frac{\sin\left(2\pi + \frac{2\pi}{15}\right)}{\sin\frac{2\pi}{15}} = \frac{\sin\frac{2\pi}{15}}{\sin\frac{2\pi}{15}} = 1 \qquad \text{ពិត}$$

ដូចនេះ $\boxed{16\cos\frac{2\pi}{15}\cos\frac{4\pi}{15}\cos\frac{8\pi}{15}\cos\frac{16\pi}{15} = 1}$

លំហាត់ទី ១១៩. រកគ្រប់តម្លៃនៃ $x \in (-\pi, \pi)$ ដែលផ្ទៀងផ្ទាត់ $8^{1+|\cos x|+|\cos^2 x|+|\cos^3 x|+\cdots} = 4^3$ ។

ដំណោះស្រាយ

គេមាន $8^{1+|\cos x|+|\cos^2 x|+|\cos^3 x|+\cdots} = 4^3$

$$2^{3(1+|\cos x|+|\cos^2 x|+|\cos^3 x|+\cdots)} = 2^6$$

$$3(1+|\cos x|+|\cos^2 x|+|\cos^3 x|+\cdots) = 6$$

$$1+|\cos x|+|\cos^2 x|+|\cos^3 x|+\cdots = 2$$

$$\frac{1}{1-|\cos x|} = 2 \qquad (\text{ ផលបូកតួនៃស្វ៊ីតធរណីមាត្រអនន្តតួ })$$

$$1-|\cos x| = \frac{1}{2} \iff |\cos x| = \frac{1}{2} \iff \cos x = \pm\frac{1}{2}$$

ចំពោះ $x \in (-\pi, \pi)$ គេបាន $x = \frac{\pi}{3}, x = -\frac{\pi}{3}, x = \frac{2\pi}{3}, x = -\frac{2\pi}{3}$

ដូចនេះ $\boxed{x = \frac{\pi}{3}, x = -\frac{\pi}{3}, x = \frac{2\pi}{3}, x = -\frac{2\pi}{3}}$

លំហាត់ទី ១២០. បង្ហាញថា $\tan x + 2\tan 2x + 4\tan 4x + 8\cot 8x = \cot x$ ។

ដំណោះស្រាយ

គេដឹងថា $\tan 2x = \dfrac{2\tan x}{1-\tan^2 x} \Longrightarrow \dfrac{1-\tan^2 x}{2\tan x} = \cot 2x \Longrightarrow \cot x - \tan x = 2\cot 2x$

គេបាន $\tan x + 2\tan x + 4\tan 4x + 8\cot 8x$

$$= \tan x + 2\tan 2x + 4\tan 4x + 4\times 2\cot(2\cdot 4x)$$

$$= \tan x + 2\tan 2x + 4\tan 4x + 4(\cot 4x - \tan 4x)$$

$$= \tan x + 2\tan 2x + 4\tan 4x + 4\cot 4x - 4\tan 4x$$

$$= \tan x + 2\tan 2x + 4\cot 4x$$

$$= \tan x + 2\tan 2x + 2\times 2\cot(2\cdot 2x)$$

$$= \tan x + 2\tan 2x + 2(\cot 2x - \tan 2x)$$

$$= \tan x + 2\tan 2x + 2\cot 2x - 2\tan 2x$$

$$= \tan x + 2\cot 2x$$

$$= \tan x + (\cot x - \tan x) = \cot x$$ ពិត

ដូចនេះ $\boxed{\tan x + 2\tan 2x + 4\tan 4x + 8\cot 8x = \cot x}$

លំហាត់ទី ១២១. រកតម្លៃនៃចំនួនពិតវិជ្ជមានតូចបំផុត x (គិតជាដឺក្រេ) ដែលផ្ទៀងផ្ទាត់ $\tan(x + 100^\circ) = \tan(x + 50^\circ)\tan x\tan(x - 50^\circ)$ ។

ដំណោះស្រាយ

គេមាន $\tan(x + 100^\circ) = \tan(x + 50^\circ)\tan x\tan(x - 50^\circ)$

$$\frac{\tan(x + 100^\circ)}{\tan x} = \tan(x + 50^\circ)\tan(x - 50^\circ)$$

$$\frac{\sin(x + 100^\circ)\cos x}{\cos(x + 100^\circ)\sin x} = \frac{\sin(x + 50^\circ)\sin(x - 50^\circ)}{\cos(x + 50^\circ)\cos(x - 50^\circ)}$$

$$\frac{\sin(2x + 100^\circ) + \sin 100^\circ}{\sin(2x + 100^\circ) - \sin 100^\circ} = \frac{\cos 100^\circ - \cos 2x}{\cos 100^\circ + \cos 2x}$$

$$\frac{\sin(2x + 100^\circ) - \sin 100^\circ + 2\sin 100^\circ}{\sin(2x + 100^\circ) - \sin 100^\circ} = \frac{\cos 100^\circ + \cos 2x - 2\cos 2x}{\cos 100^\circ + \cos 2x}$$

$$1 + \frac{2\sin 100^\circ}{\sin(2x + 100^\circ) - \sin 100^\circ} = 1 + \frac{-2\cos 2x}{\cos 100^\circ + \cos 2x}$$

$$\frac{2\sin 100^\circ}{\sin(2x + 100^\circ) - \sin 100^\circ} = \frac{-2\cos 2x}{\cos 100^\circ + \cos 2x}$$

$$\frac{\sin(2x + 100^\circ) - \sin 100^\circ}{2\sin 100^\circ} = \frac{\cos 100^\circ + \cos 2x}{-2\cos 2x}$$

$$\frac{\sin(2x + 100^\circ)}{\sin 100^\circ} - 1 = \frac{-\cos 100^\circ}{\cos 2x} - 1$$

$$\frac{\sin(2x + 100^\circ)}{\sin 100^\circ} = \frac{-\cos 100^\circ}{\cos 2x}$$

$$\sin(2x + 100^\circ)\cos 2x = -2\sin 100^\circ\cos 100^\circ$$

$$\frac{1}{2}[\sin(2x + 100^\circ + 2x) + \sin(2x + 100^\circ - 2x)] = -\sin 100^\circ\cos 100^\circ$$

$$\sin(4x + 100^\circ) + \sin 100^\circ = -2\sin 100^\circ\cos 100^\circ = -\sin 200^\circ$$

$$\sin(4x + 10^\circ + 90^\circ) + \sin(90^\circ + 10^\circ) = -\sin(180^\circ + 20^\circ)$$

$$\cos(4x + 10^\circ) + \cos 10^\circ = -(-\sin 20^\circ) = \sin 20^\circ$$

$$\cos(4x + 10^\circ) = \sin 20^\circ - \cos 10^\circ = \sin 20^\circ - \sin 80^\circ$$

$$\cos(4x+10^\circ)=2\sin\frac{20^\circ-80^\circ}{2}\cos\frac{20^\circ+80^\circ}{2}=2\sin(-30^\circ)\cos 50^\circ$$

$$\cos(4x+10^\circ)=-2\sin 30^\circ\cos 50^\circ=-2\cdot\frac{1}{2}\cos 50^\circ=-\cos 50^\circ$$
$$=\cos(180^\circ-50^\circ)=\cos 130^\circ$$

គេបាន $\cos(4x+10^\circ)=\cos 130^\circ \Longrightarrow 4x+10^\circ=130^\circ \Longrightarrow x=30^\circ$

ដូចនេះ $\boxed{x=30^\circ}$

លំហាត់ទី ១២២. ស្វ៊ីត (a_n) បំពេញលក្ខខណ្ឌខាងក្រោមចំពោះគ្រប់ $n=1,2,3,\dots$ ។

$$\sum_{k=1}^{n}\frac{1}{k}\left(a_k+\frac{1}{k+1}\right)=2^n+1-\frac{1}{n+1} \text{ ។}$$

ក. រកតួទី n នៃស្វ៊ីត (a_n) ជាអនុគមន៍នៃ n ។

ខ. គណនា $\sum_{k=1}^{n}a_k$ ។

ដំណោះស្រាយ

ក. រកតួទី n នៃស្វ៊ីត (a_n) ជាអនុគមន៍នៃ n

គេមាន $\sum_{k=1}^{n}\frac{1}{k}\left(a_k+\frac{1}{k+1}\right)=2^n+1-\frac{1}{n+1}$ $\quad(1)$

តាង $S_n=\sum_{k=1}^{n}\frac{1}{k}\left(a_k+\frac{1}{k+1}\right)$

$$\Longrightarrow S_{n+1}=\sum_{k=1}^{n+1}\frac{1}{k}\left(a_k+\frac{1}{k+1}\right)$$
$$=\left[\sum_{k=1}^{n}\frac{1}{k}\left(a_k+\frac{1}{k+1}\right)\right]+\frac{1}{n+1}\left(a_{n+1}+\frac{1}{n+1}\right)$$
$$=S_n+\frac{1}{n+1}\left(a_{n+1}+\frac{1}{n+2}\right)$$

នាំឱ្យ $a_{n+1}=(n+1)(S_{n+1}-S_n)-\frac{1}{n+2}$

តាម (1) គេបាន $S_n=2^n+1-\frac{1}{n+1}\Longrightarrow S_{n+1}=2^{n+1}+1-\frac{1}{n+2}$

នាំឱ្យ $S_{n+1}-S_n=2^{n+1}+1-\frac{1}{n+2}-2^n-1+\frac{1}{n+1}=2^n+\frac{1}{n+1}-\frac{1}{n+2}$

គេបាន $a_{n+1}=(n+1)\left(2^n+\frac{1}{n+1}-\frac{1}{n+2}\right)-\frac{1}{n+2}$

$$=(n+1)2^n+n-\frac{n+1}{n+2}-\frac{1}{n+2}=(n+1)2^n$$

នាំឱ្យ $a_{n+1}=(n+1)2^n$ ដែល $n=1,2,3\dots$

គេបាន $a_n=n2^{n-1}$ ដែល $n=2,3,4,\dots$ ។

ចំពោះ $n=1$ តាម (1) គេបាន $a_1+\frac{1}{2}=2+1-\frac{1}{2}\Longleftrightarrow a_1=2$

ដូចនេះ $\boxed{a_1=2 \text{ និង } a_n=n2^{n-1}\ , n\geq 2}$

ខ. គណនា $\sum\limits_{k=1}^{n}a_k$

តាង $L_n=\sum\limits_{k=1}^{n}=a_1+a_2+a_3+\cdots+a_n$

$$=2+2\times 2+3\times 2^2+4\times 2^3+\cdots+n\times 2^{n-1}\quad (2)$$

$$\Longrightarrow 2L_n=2\times 2+2\times 2^2+3\times 2^3+\cdots+(n-1)2^{n-1}+n\times 2^n\quad (3)$$

យក (2) − (3) គេបាន

$$L_n-2L_n=2+2^2+2^3+\cdots+2^{n-1}-n\times 2^n$$

$$-L_n=\frac{2(2^{n-1}-1)}{2-1}-n\times 2^n=2(2^{n-1}-1)-n\times 2^n=2^n-2-n\times 2^n$$

សម្គាល់

ផលបូក n តួដំបូងនៃស្វ៊ីតធរណីមាត្រ

$$S_n=\frac{u_1(q^n-1)}{q-1},\quad q\neq 1$$

គេបាន $L_n=-2^n+2+n\times 2^n=(n-1)2^n+2$

ដូចនេះ $\boxed{\sum\limits_{k=1}^{n}a_k=(n-1)2^n+2}$

លំហាត់ទី ១២៣. គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to 1}\dfrac{\sqrt[3]{x^2}-2\sqrt[3]{x}+1}{(x-1)^2}$

ខ. $\lim\limits_{x\to 3}\left[\log_a\left(\dfrac{x-3}{\sqrt{x+6}-3}\right)\right]\quad , a>0, a\neq 1$

គ. $\lim\limits_{x\to 0}\dfrac{1-\cos^3 x}{x\sin x\cos x}$

ដំណោះស្រាយ

ក. $$\lim_{x\to 1}\frac{\sqrt[3]{x^2}-2\sqrt[3]{x}+1}{(x-1)^2}=\lim_{x\to 1}\frac{(\sqrt[3]{x}-1)^2}{(x-1)^2}$$

$$=\lim_{x\to 1}\left(\frac{\sqrt[3]{x}-1}{x-1}\right)^2=\lim_{x\to 1}\left[\frac{(\sqrt[3]{x}-1)(\sqrt[3]{x^2}+\sqrt[3]{x}+1)}{(x-1)(\sqrt[3]{x^2}+\sqrt[3]{x}+1)}\right]^2$$

$$=\lim_{x\to 1}\left(\frac{x-1}{(x-1)(\sqrt[3]{x^2}+\sqrt[3]{x}+1)}\right)^2=\lim_{x\to 1}\left(\frac{1}{\sqrt[3]{x^2}+\sqrt[3]{x}+1}\right)^2=\frac{1}{9}$$

ដូចនេះ $\boxed{\lim_{x\to1}\frac{\sqrt[3]{x^2}-2\sqrt[3]{x}+1}{(x-1)^2}=\frac{1}{9}}$

ខ. $$\lim_{x\to3}\left[\log_a\left(\frac{x-3}{\sqrt{x+6}-3}\right)\right]=\lim_{x\to3}\left[\log_a\left(\frac{(x-3)(\sqrt{x+6}+3)}{(\sqrt{x+6}-3)(\sqrt{x+6}+3)}\right)\right]$$
$$=\lim_{x\to3}\left[\log_a\left(\frac{(x-3)(\sqrt{x+6}+3)}{(x+6)-9}\right)\right]$$
$$=\lim_{x\to3}\left[\log_a\left(\frac{(x-3)(\sqrt{x+6}+3)}{x-3}\right)\right]$$
$$=\lim_{x\to3}\left[\log_a\left(\sqrt{x+6}+3\right)\right]=\log_a 6$$

ដូចនេះ $\boxed{\lim_{x\to3}\left[\log_a\left(\frac{x-3}{\sqrt{x+6}-3}\right)\right]=\log_a 6}$

គ. $$\lim_{x\to0}\frac{1-\cos^3 x}{x\sin x\cos x}=\lim_{x\to0}\frac{(1-\cos x)(1+\cos x+\cos^2 x)}{x\sin x\cos x}$$
$$=\lim_{x\to0}\frac{2\sin^2\frac{x}{2}(1+\cos x+\cos^2 x)}{2x\sin\frac{x}{2}\cos\frac{x}{2}\cos x}$$
$$=\lim_{x\to0}\frac{\sin\frac{x}{2}(1+\cos x+\cos^2 x)}{x\cos\frac{x}{2}\cos x}$$
$$=\lim_{x\to0}\left(\frac{\sin\frac{x}{2}}{\frac{x}{2}}\times\frac{1+\cos x+\cos^2 x}{2\cos\frac{x}{2}\cos x}\right)$$
$$=1\times\frac{1+1+1}{2}=\frac{3}{2}$$

ដូចនេះ $\boxed{\lim_{x\to0}\frac{1-\cos^3 x}{x\sin x\cos x}=\frac{3}{2}}$

លំហាត់ទី ១២៤. គណនាលីមីតខាងក្រោម

ក. $\lim_{x\to1}\sum_{r=1}^{n}\frac{x^r-1}{x-1}$

ខ. $\lim_{n\to+\infty}\frac{1}{n^4}\left[\left(\sum_{k=1}^{n}k\right)+2\left(\sum_{k=1}^{n-1}k\right)+3\left(\sum_{k=1}^{n-2}k\right)+\cdots+n\right]$

គ. $\lim_{n\to+\infty}\prod_{r=3}^{n}\left(\frac{r^3-1}{r^3+1}\right)$

ដំណោះស្រាយ

ក. $\lim\limits_{x\to1}\sum\limits_{r=1}^{n}\dfrac{x^r-1}{x-1}=\lim\limits_{x\to1}\sum\limits_{r=1}^{n}\dfrac{(x-1)(x^{r-1}+x^{r-1}+\cdots+1)}{x-1}$

$$=\lim_{x\to1}\sum_{r=1}^{n}\left(x^{r-1}+x^{r-2}+\cdots+x+1\right)$$

$$=\sum_{r=1}^{n}r=1+2+3+\cdots+n=\frac{n(n+1)}{2}$$

ដូចនេះ $\boxed{\lim\limits_{x\to1}\sum\limits_{r=1}^{n}\dfrac{x^r-1}{x-1}=\dfrac{n(n+1)}{2}}$

ខ. តាង $S_n=\left(\sum\limits_{k=1}^{n}k\right)+2\left(\sum\limits_{k=1}^{n-1}k\right)+3\left(\sum\limits_{k=1}^{n-2}k\right)+\cdots+n$

និង $a_{r+1}=(r+1)\sum\limits_{k=1}^{n-r}k=(r+1)[1+2+3+\cdots+(n-r)]$

$$=(r+1)\times\frac{(n-r)[(n-r)+1]}{2}=\frac{1}{2}(r+1)(n-r)(n-r+1)$$

$$=\frac{1}{2}(r+1)[(n-r)^2+(n-r)]=\frac{1}{2}(r+1)(n^2-2nr+r^2+n-r)$$

$$=\frac{1}{2}(r+1)[r^2-(2n+1)r+n^2+n]$$

$$=\frac{1}{2}[r^3-(2n+1)r^2+(n^2+n)r+r^2-(2n+1)r+n^2+n]$$

$$=\frac{1}{2}[r^3-2nr^2+(n^2-n-1)r+n^2+n]$$

គេបាន $S_n=\sum\limits_{r=0}^{n-1}a_{r+1}=\dfrac{1}{2}\sum\limits_{r=0}^{n-1}[r^3-2nr^2+(n^2-n-1)r+n^2+n]$

$$=\frac{1}{2}\left[\sum_{r=0}^{n-1}r^3-2n\sum_{r=0}^{n-1}r^2+(n^2-n-1)\sum_{r=0}^{n-1}r+\sum_{r=0}^{n-1}(n^2+n)\right]$$

$$=\frac{1}{2}\left\{\left[\frac{n(n-1)}{2}\right]^2-2n\times\frac{(n-1)n(2n-1)}{6}+(n^2-n-1)\times\frac{n(n-1)}{2}\right.$$

$$\left.+(n^2+n)\times(n-1)\right\}$$

$$=\frac{n-1}{24}\left[3n^2(n-1)-4n^2(2n-1)+6n(n^2-n-1)+12(n^2+n)\right]$$

$$=\frac{n-1}{24}\left(3n^3-3n^2-8n^3+4n^2+6n^3-6n^2-6n+12n^2+12n\right)$$

$$= \frac{n-1}{24} \times (n^3 + 7n^2 + 6n)$$

$$= \frac{1}{24} n(n-1)(n^2 + 7n + 6)$$

នាំឱ្យ $\lim\limits_{n\to+\infty} \frac{1}{n^4} S_n = \lim\limits_{n\to+\infty} \frac{n(n-1)(n^2+7n+6)}{24n^4} = \frac{1}{24}$

ដូចនេះ $\boxed{\lim\limits_{n\to+\infty} \frac{1}{n^4}\left[\left(\sum_{k=1}^{n} k\right) + 2\left(\sum_{k=1}^{n-1} k\right) + 3\left(\sum_{k=1}^{n-2} k\right) + \cdots + n\right] = \frac{1}{24}}$

គ. គេមាន $\frac{r^3-1}{r^3+1} = \frac{(r-1)(r^2+r+1)}{(r+1)(r^2-r+1)} = \frac{r-1}{r+1} \times \frac{r^2+r+1}{r^2-r+1}$

$$= \frac{r-1}{r+1} \times \frac{r^2+r+1}{(r-1)^2+(r-1)+1}$$

គេបាន $\prod\limits_{r=3}^{n} \left(\frac{r^3-1}{r^3+1}\right) = \prod\limits_{r=3}^{n} \left[\frac{r-1}{r+1} \times \frac{r^2+r+1}{(r-1)^2+(r-1)+1}\right]$

$$= \prod_{r=3}^{n} \left(\frac{r-1}{r+1}\right) \times \prod_{r=3}^{n} \frac{r^2+r+1}{(r-1)^2+(r-1)+1}$$

ដោយ $\prod\limits_{r=3}^{n} \left(\frac{r-1}{r+1}\right) = \frac{2}{4} \times \frac{3}{5} \times \frac{4}{6} \times \frac{5}{7} \times \cdots \times \frac{n-3}{n-1} \times \frac{n-2}{n} \times \frac{n-1}{n+1}$

$$= \frac{2\times 3}{n(n+1)} = \frac{6}{n(n+1)} = \frac{6}{n^2+n}$$

និង $\prod\limits_{r=3}^{n} \frac{r^2+r+1}{(r-1)^2+(r-1)+1} = \frac{3^2+3+1}{2^2+2+1} \times \frac{4^2+4+1}{3^2+3+1} \times \cdots \times \frac{n^2+n+1}{(n-1)^2+(n-1)+1}$

$$= \frac{n^2+n+1}{2^2+2+1} = \frac{n^2+n+1}{7}$$

គេបាន $\lim\limits_{n\to+\infty} \prod\limits_{r=3}^{n} \left(\frac{r^3-1}{r^3+1}\right) = \lim\limits_{n\to+\infty} \left(\frac{6}{n^2+n} \times \frac{n^2+n+1}{7}\right) = \frac{6}{7}$

ដូចនេះ $\boxed{\lim\limits_{n\to+\infty} \prod\limits_{r=3}^{n} \left(\frac{r^3-1}{r^3+1}\right) = \frac{6}{7}}$

លំហាត់ទី ១២៥. គណនាលីមីត $\lim\limits_{n\to+\infty} \frac{1}{n^3}\left(\sum_{k=1}^{n} \lfloor k^2 x \rfloor\right)$ ដែល $\lfloor x \rfloor$ តាងឱ្យផ្នែកគត់ធំបំផុត $\le x$ ។

ដំណោះស្រាយ

គេមាន $k^2x - 1 < \lfloor k^2x \rfloor \le k^2x \Longrightarrow \sum_{k=1}^{n}\left(k^2x-1\right) < \sum_{k=1}^{n}\lfloor k^2x \rfloor \le \sum_{k=1}^{n}(k^2x) \qquad (1)$

ដោយ $\sum_{k=1}^{n}\left(k^2x-1\right) = x\sum_{k=1}^{n}k^2 - \sum_{k=1}^{n}1 = x \times \frac{n(n+1)(2n+1)}{6} - n$

និង $\sum_{k=1}^{n}(k^2x) = x\sum_{k=1}^{n}k^2 = x \times \frac{n(n+1)(2n+1)}{6}$

តាម (1) គេបាន $x \times \frac{n(n+1)(2n+1)}{6} - n < \sum_{k=1}^{n}\lfloor k^2x \rfloor \le x \times \frac{n(n+1)(2n+1)}{6}$

$$\Longrightarrow \frac{1}{n^3}\left[x \times \frac{n(n+1)(2n+1)}{6} - n\right] < \frac{1}{n^3}\sum_{k=1}^{n}\lfloor k^2x \rfloor \le \frac{1}{n^3}\left[x \times \frac{n(n+1)(2n+1)}{6}\right]$$

$$\Longrightarrow x \times \frac{(n+1)(2n+1)}{6n^2} - \frac{1}{n^2} < \frac{1}{n^3}\sum_{k=1}^{n}\lfloor k^2x \rfloor \le x \times \frac{(n+1)(2n+1)}{6n^2}$$

$$\lim_{n\to+\infty}\left[\frac{x(n+1)(2n+1)}{6n^2} - \frac{1}{n^2}\right] < \lim_{n\to+\infty}\left(\frac{1}{n^3}\sum_{k=1}^{n}\lfloor k^2x \rfloor\right) \le \lim_{n\to+\infty}\left[\frac{x(n+1)(2n+1)}{6n^2}\right]$$

$$\Longrightarrow \frac{x}{3} < \lim_{n\to+\infty}\left(\frac{1}{n^3}\sum_{k=1}^{n}\lfloor k^2x \rfloor\right) \le \frac{x}{3} \Longrightarrow \lim_{n\to+\infty}\left(\frac{1}{n^3}\sum_{k=1}^{n}\lfloor k^2x \rfloor\right) = \frac{x}{3}$$

ដូចនេះ $\boxed{\lim_{n\to+\infty}\left(\frac{1}{n^3}\sum_{k=1}^{n}\lfloor k^2x \rfloor\right) = \frac{x}{3}}$

លំហាត់ទី ១២៦. គណនាលីមីត $\lim_{n\to+\infty}\left(\cos\frac{x}{2}\cos\frac{x}{2^2}\cos\frac{x}{2^3}\cdots\cos\frac{x}{2^n}\right)$ ។

ដំណោះស្រាយ

តាមទំនាក់ទំនង $\sin 2a = 2\sin a\cos a \Longrightarrow \cos a = \frac{\sin 2a}{\sin a}$

យក $a = \frac{x}{2}, \frac{x}{2^2}, \frac{x}{2^3}, \ldots, \frac{x}{2^n}$

គេបាន $\cos\frac{x}{2}\cos\frac{x}{2^2}\cos\frac{x}{2^3}\cdots\cos\frac{x}{2^n}$

$$= \frac{\sin x}{2\sin\frac{x}{2}} \times \frac{\sin\frac{x}{2}}{2\sin\frac{x}{2^2}} \times \frac{\sin\frac{x}{2^2}}{2\sin\frac{x}{2^3}} \times \frac{\sin\frac{x}{2^{n-2}}}{2\sin\frac{x}{2^{n-1}}} \times \frac{\sin\frac{x}{2^{n-1}}}{2\sin\frac{x}{2^n}}$$

$$= \frac{1}{2^n} \times \frac{\sin x}{\sin \frac{x}{2^n}} = \frac{\sin x}{2^n \sin \frac{x}{2^n}}$$

នាំឱ្យ $\lim\limits_{n\to+\infty}\left(\cos\frac{x}{2}\cos\frac{x}{2^2}\cos\frac{x}{2^3}\cdots\cos\frac{x}{2^n}\right) = \lim\limits_{n\to+\infty}\left(\frac{\sin x}{2^n \sin\frac{x}{n^n}}\right)$

$$= \frac{\sin x}{x}\lim_{n\to+\infty}\left[\frac{\frac{x}{2^n}}{\sin\frac{x}{2^n}}\right] = \frac{\sin x}{x}$$

ដូចនេះ $\boxed{\lim\limits_{n\to+\infty}\left(\cos\frac{x}{2}\cos\frac{x}{2^2}\cos\frac{x}{2^3}\cdots\cos\frac{x}{2^n}\right) = \frac{\sin x}{x}}$

លំហាត់ទី ១២៧. គណនាលីមីត $\lim\limits_{n\to+\infty}\left(\frac{7}{10}+\frac{29}{10^2}+\frac{133}{10^3}+\cdots+\frac{5^n+2^n}{10^n}\right)$ ។

ដំណោះស្រាយ

គេមាន $\lim\limits_{n\to+\infty}\left(\frac{7}{10}+\frac{29}{10^2}+\frac{133}{10^3}+\cdots+\frac{5^n+2^n}{10^n}\right) = \lim\limits_{n\to+\infty}\sum\limits_{k=1}^{n}\left(\frac{5^k+2^k}{10^k}\right)$

$$= \lim_{n\to+\infty}\sum_{k=1}^{n}\left[\left(\frac{1}{2}\right)^k+\left(\frac{1}{5}\right)^n\right]$$

$$= \lim_{n\to+\infty}\left[\sum_{k=1}^{n}\left(\frac{1}{2}\right)^k+\sum_{k=1}^{n}\left(\frac{1}{5}\right)^k\right]$$

$$= \lim_{n\to+\infty}\left[\frac{\frac{1}{2}\left(1-\frac{1}{2^n}\right)}{1-\frac{1}{2}}+\frac{\frac{1}{5}\left(1-\frac{1}{5^n}\right)}{1-\frac{1}{5}}\right]$$

$$= \lim_{n\to+\infty}\left[1-\frac{1}{2^n}+\frac{1}{4}\left(1-\frac{1}{5^n}\right)\right] = 1+\frac{1}{4} = \frac{5}{4}$$

ដូចនេះ $\boxed{\lim\limits_{n\to+\infty}\left(\frac{7}{10}+\frac{29}{10^2}+\frac{133}{10^3}+\cdots+\frac{5^n+2^n}{10^n}\right) = \frac{5}{4}}$

លំហាត់ទី ១២៨. គណនាលីមីត $\lim\limits_{n\to+\infty}\left(\tan\theta+\frac{1}{2}\tan\frac{\theta}{2}+\frac{1}{2}\tan\frac{\theta}{2^2}+\cdots+\frac{1}{2^n}\tan\frac{\theta}{2^n}\right)$

ដំណោះស្រាយ

គេមាន $\cot 2x = \frac{\cos 2x}{\sin 2x} = \frac{\cos^2 x-\sin^2 x}{2\sin x\cos x}$

$$= \frac{\cos^2 x}{2\sin x\cos x}-\frac{\sin^2 x}{2\sin x\cos x} = \frac{1}{2}\cot x-\frac{1}{2}\tan x$$

$\Longrightarrow \tan x = \cot x - 2\cot 2x$ យក $x = \theta, \frac{\theta}{2}, \frac{\theta}{2^2}, \dots, \frac{\theta}{2^n}$

គេបាន $\lim\limits_{n\to+\infty}\left(\tan\theta + \frac{1}{2}\tan\frac{\theta}{2} + \frac{1}{2}\tan\frac{\theta}{2^2} + \cdots + \frac{1}{2^n}\tan\frac{\theta}{2^n}\right)$

$$= \lim_{n\to+\infty}\left[(\cot\theta - 2\cot 2\theta) + \left(\frac{1}{2}\cot\frac{\theta}{2} - \cot\theta\right) + \left(\frac{1}{2^2}\cot\frac{\theta}{2^2} - \frac{1}{2}\cot\frac{\theta}{2}\right) + \cdots \right.$$

$$\left. \cdots + \left(\frac{1}{2^n}\cot\frac{\theta}{2^n} - \frac{1}{2^{n-1}}\cot\frac{\theta}{2^{n-1}}\right)\right]$$

$$= \lim_{n\to+\infty}\left[\frac{1}{2^n}\cot\frac{\theta}{2^n} - 2\cot 2\theta\right]$$

$$= -2\cot\theta + \frac{1}{\theta}\lim_{n\to+\infty}\left(\frac{\frac{\theta}{2^n}}{\tan\frac{\theta}{2^n}}\right) = -2\cot\theta + \frac{1}{\theta}$$

ដូចនេះ $\boxed{\lim\limits_{n\to+\infty}\left(\tan\theta + \frac{1}{2}\tan\frac{\theta}{2} + \frac{1}{2}\tan\frac{\theta}{2^2} + \cdots + \frac{1}{2^n}\tan\frac{\theta}{2^n}\right) = \frac{1}{\theta} - 2\cot\theta}$

លំហាត់ទី ១២៩. គណនាលីមីត $\lim\limits_{x\to 0}\frac{\tan(\lfloor -\pi^2\rfloor x^2) - x^2\tan(\lfloor -\pi^2\rfloor)}{\sin^2 x}$ ។

ដំណោះស្រាយ

គេមាន $\lfloor -\pi^2\rfloor = \lfloor -9.8696\dots\rfloor = -10$

គេបាន $\lim\limits_{x\to 0}\frac{\tan(\lfloor -\pi^2\rfloor x^2) - x^2\tan(\lfloor -\pi^2\rfloor)}{\sin^2 x} = \lim\limits_{x\to 0}\frac{\tan(-10x^2) - x^2\tan(-10)}{\sin^2 x}$

$$= \lim_{x\to 0}\frac{-\tan(10x^2) + x^2\tan 10}{\sin^2 x}$$

$$= \lim_{x\to 0}\left[\frac{-\tan(10x^2)}{x^2} + \frac{x^2\tan(10)}{x^2}\right] \times \lim_{x\to 0}\frac{\sin^2 x}{x^2}$$

$$= \lim_{x\to 0}\left[-10\times\frac{\tan(10x^2)}{10x^2} + \tan(10)\right]\times 1$$

$$= -10 + \tan(10)$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\frac{\tan(\lfloor -\pi^2\rfloor x^2) - x^2\tan(\lfloor -\pi^2\rfloor)}{\sin^2 x} = \tan(10) - 10}$

លំហាត់ទី ១៣០. គណនាលីមីត $\lim\limits_{h\to 0}\dfrac{2\left[\sqrt{3}\sin\left(\dfrac{\pi}{6}+h\right)-\cos\left(\dfrac{\pi}{6}+h\right)\right]}{\sqrt{3}h(\sqrt{3}\cos h-\sin h)}$ ។

ដំណោះស្រាយ

គេមាន $\lim\limits_{h\to 0}\dfrac{2\left[\sqrt{3}\sin\left(\dfrac{\pi}{6}+h\right)-\cos\left(\dfrac{\pi}{6}+h\right)\right]}{\sqrt{3}h(\sqrt{3}\cos h-\sin h)}$

$$=\lim_{h\to 0}\frac{2\left[\sqrt{3}\left(\sin\dfrac{\pi}{6}\cos h+\sin h\cos\dfrac{\pi}{6}\right)-\left(\cos\dfrac{\pi}{6}\cos h-\sin\dfrac{\pi}{6}\sin h\right)\right]}{\sqrt{3}h(\sqrt{3}\cos h-\sin h)}$$

$$=\lim_{h\to 0}\frac{2\left[\sqrt{3}\left(\dfrac{1}{2}\cos h+\dfrac{\sqrt{3}}{2}\sin h\right)-\left(\dfrac{\sqrt{3}}{2}\cos h-\dfrac{1}{2}\sin h\right)\right]}{\sqrt{3}h(\sqrt{3}\cos h-\sin h)}$$

$$=\lim_{h\to 0}\frac{2\left(\dfrac{\sqrt{3}}{2}\cos h+\dfrac{3}{2}\sin h-\dfrac{\sqrt{3}}{2}\cos h+\dfrac{1}{2}\sin h\right)}{\sqrt{3}h(\sqrt{3}\cos h-\sin h)}$$

$$=\lim_{h\to 0}\frac{4\sin h}{\sqrt{3}h(\sqrt{3}\cos h-\sin h)}=\lim_{h\to 0}\left(\frac{\sin h}{h}\times\frac{4}{\sqrt{3}(\sqrt{3}\cos h-\sin h)}\right)=\frac{4}{3}$$

ដូចនេះ $\boxed{\lim\limits_{h\to 0}\dfrac{2\left[\sqrt{3}\sin\left(\dfrac{\pi}{6}+h\right)-\cos\left(\dfrac{\pi}{6}+h\right)\right]}{\sqrt{3}h(\sqrt{3}\cos h-\sin h)}=\dfrac{4}{3}}$

លំហាត់ទី ១៣១. គេឱ្យ $f(x)=x-\lfloor x\rfloor$ ។ គណនាលីមីត $\lim\limits_{n\to+\infty}\dfrac{[f(x)]^{2n}-1}{[f(x)]^{2n}+1}$ ។

ដំណោះស្រាយ

គេមាន $0\le x-\lfloor x\rfloor<1\Longleftrightarrow\forall x\in\mathbb{R},\ 0\le f(x)<1$ នាំឱ្យ $\lim\limits_{n\to+\infty}[f(x)]^{2n}=0$

គេបាន $\lim\limits_{n\to+\infty}\dfrac{[f(x)]^{2n}-1}{[f(x)]^{2n}+1}=\dfrac{0-1}{0+1}=-1$

ដូចនេះ $\boxed{\lim\limits_{n\to+\infty}\dfrac{[f(x)]^{2n}-1}{[f(x)]^{2n}+1}=-1}$

លំហាត់ទី ១៣២. គណនាលីមីត $\lim\limits_{x\to 0}\dfrac{729^x-243^x-81^x+9^x+3^x-1}{x^3}$ ។

ដំណោះស្រាយ

គេមាន $\lim\limits_{x\to 0}\dfrac{729^x-243^x-81^x+9^x+3^x-1}{x^3}$

$$
\begin{aligned}
&=\lim_{x\to 0}\frac{3^{6x}-3^{5x}-3^{4x}+3^{2x}+3^x-1}{x^3}\\
&=\lim_{x\to 0}\frac{3^{5x}(3^x-1)-3^{2x}(3^{2x}-1)+(3^x-1)}{x^3}\\
&=\lim_{x\to 0}\frac{3^{5x}(3^x-1)-3^{2x}(3^x-1)(3^x+1)+(3^x-1)}{x^3}\\
&=\lim_{x\to 0}\frac{(3^x-1)(3^{5x}-3^{3x}-3^{2x}+1)}{x^3}\\
&=\lim_{x\to 0}\frac{(3^x-1)[3^{3x}(3^{2x}-1)-(3^{2x}-1)]}{x^3}\\
&=\lim_{x\to 0}\frac{(3^x-1)(3^{2x}-1)(3^{3x}-1)}{x^3}\\
&=\lim_{x\to 0}\left[\frac{3^x-1}{x}\times\frac{3^{2x}-1}{2x}\times\frac{3^{3x}-1}{3x}\times 2\times 3\right]\\
&=6\ln 3\times\ln 3\times\ln 3=6\ln^3 3
\end{aligned}
$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\dfrac{729^x-243^x-81^x+9^x+3^x-1}{x^3}=6\ln^3 3}$

លំហាត់ទី ១៣៣. គេឱ្យ α និង β ជាឫសនៃសមីការដឺក្រេទី២ $ax^2+bx+c=0$ ។

គណនាលីមីត $\lim\limits_{x\to\alpha}(1+ax^2+bx+c)^{\frac{1}{x-\alpha}}$ ។

ដំណោះស្រាយ

គេមាន α និង β ជាឫសនៃសមីការដឺក្រេទី២ $ax^2+bx+c=0$

$\Longrightarrow ax^2+bx+c=a(x-\alpha)(x-\beta)$

គេបាន $\lim\limits_{x\to\alpha}(1+ax^2+bx+c)^{\frac{1}{x-\alpha}}=\lim\limits_{x\to\alpha}\left[1+(ax^2+bx+c)\right]^{\frac{1}{x-\alpha}}$

$$
\begin{aligned}
&=\lim_{x\to\alpha}\left\{\left[1+(ax^2+bx+c)\right]^{\frac{1}{ax^2+bx+c}}\right\}^{\frac{ax^2+bx+c}{x-\alpha}}\\
&=e^{\lim\limits_{x\to\alpha}\frac{ax^2+bx+c}{x-\alpha}}=e^{\lim\limits_{x\to\alpha}\frac{a(x-\alpha)(x-\beta)}{x-\alpha}}\\
&=e^{\lim\limits_{x\to\alpha}a(x-\beta)}=e^{a(\alpha-\beta)}
\end{aligned}
$$

ដូចនេះ $\boxed{\lim\limits_{x\to\alpha}(1+ax^2+bx+c)^{\frac{1}{x-\alpha}}=e^{a(\alpha-\beta)}}$

លំហាត់ទី ១៣៤. គណនាលីមីតខាងក្រោម

ក. $\lim_{x\to a}\left(\frac{\sin x}{\sin a}\right)^{\frac{1}{x-a}}$, $a\neq k\pi,\ k\in\mathbb{Z}$

ខ. $\lim_{x\to 0}\left(\frac{1+\tan x}{1-\tan x}\right)^{\frac{1}{\sin x}}$

គ. $\lim_{x\to a}\left(2-\frac{x}{a}\right)^{\tan\frac{\pi x}{2a}}$, $a\neq 0$

ឃ. $\lim_{x\to 0}(\cos x+a\sin bx)^{\frac{a}{x}}$

ង. $\lim_{x\to 0}\left(\frac{\sin x}{x}\right)^{\frac{\sin x}{x-\sin x}}$

ច. $\lim_{x\to -1}\left(\frac{x^4+x^2+x+1}{x^2-x+1}\right)^{\frac{1-\cos(x+1)}{(x+1)^2}}$

ឆ. $\lim_{n\to +\infty}\left(\cos\frac{x}{n}\right)^{n}$

ដំណោះស្រាយ

